N: 2

15-1-97

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៥ លេខ ២ ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៧

OFFICIAL JOURNAL

រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសំរេច
- សារាចរ

ផ្សាយចេញពីទីស្តីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្តាហ៍

LAW

មាតិកា

I ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

១៥.១.៩៧	ព្រះរាជក្រឹត្យ នស/រកត/០១៩៧/០៤ តែងតាំងមុខតំណែងនិងតម្លើងឋានន្តរសក្តិនាយទាហានជាន់ខ្ពស់	២៤
១៥.១.៩៧	ព្រះរាជក្រឹត្យ នស/រកត/០១៩៧/០៥ តែងតាំងផ្លាស់ប្តូរមុខងារនាយទាហានជាន់ខ្ពស់	២៦

II ទីស្តីការគណៈរដ្ឋមន្ត្រី

១—អនុក្រឹត្យ

១០.០១.៩៧	អនុក្រឹត្យលេខ ០១ អនក្រ.បក ស្តីពីការផ្ទេរឥណទាន	២៨
១៣.០១.៩៧	អនុក្រឹត្យលេខ ០២ អនក្រ.បក ស្តីពីការប្រើប្រាស់ឥណទានឹងកជនការូបនីយកម្មសហគ្រាសសាធារណៈ	៣០

២—សេចក្តីសំរេច

១៥.០១.៩៧	សេចក្តីសំរេចលេខ ០៣ សសរ ស្តីពីការរៀបចំកិច្ចប្រជុំនៃក្រុមពិគ្រោះយោបល់លើកទី ២ (Second Consultative Group Meeting) និងកិច្ចប្រជុំគណៈកម្មាធិការអន្តរជាតិ ស្តីពីការស្តារកម្ពុជា លើកទី ៤ (4 th International Committee on the Reconstruction of Combodia)	៣២

III- ការងារបណ្តាក្រសួង

ប្រកាសអន្តរក្រសួង

១_ ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ទីស្តីការក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ

៩.០១.៩៧ ប្រកាសលេខ ០០៤ សហវ.មប្រក ស្ដីពីការបង្កើត និងតែងតាំងភ្នាក់ងារបើកផ្ដល់សំរាប់បើកបៀវត្សជូនមន្ត្រីរាជការ ៣៤

២_ និស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

និស្ដីការរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

១៥.០១.៩៧ ប្រកាសលេខ ០០៧ សហវ.មប្រក ស្ដីពីការបង្កើត និងតែងតាំងភ្នាក់ងារបើកផ្ដល់សំរាប់បើកបៀវត្សជូនមន្ត្រីរាជការ ៣៦

១៥.០១.៩៧ ប្រកាសលេខ ០០៨ សហវ.មប្រក ស្ដីពីការតែងតាំងរដ្ឋទេយ្យករបុរេប្រទាននៅក្រសួងមហាផ្ទៃ «ផ្នែករដ្ឋបាល» ៣៨

៣_ និស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ប្រកាស

៩.០១.៩៧ ប្រកាសលេខ ០៥ ប្រក.សហវ.ពដ ស្ដីពីការបង្កើតការិយាល័យចាត់ចែង ៤០

៤—និស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និងថាមពល

ប្រកាស

០៩.០១.៩៧ ប្រកាសលេខ ០៣ ផក.ប្រក អនុញ្ញាតអោយក្រុមហ៊ុន ខូលីធិតេក្សស្ទីល ខូអែលធីឌី របស់ក្រុមហ៊ុន (QUALITY TEXTILES CO LTD) តំណាងដោយលោក SEOW FUI CHEONG សញ្ជាតិ ម៉ាឡេស៊ី បង្កើតរោងចក្រកាត់ដេរសំលៀកបំពាក់នាំចេញ ៤២

៩.០១.៩៧ ប្រកាសលេខ ០៤ ផក.ប្រក អនុញ្ញាតអោយក្រុមហ៊ុន ចាយណាហ្វាម៉ែនម៉េញ៉ៃ ហ្វាក់ធឺរីង តំណាងដោយលោក CHONG CHOK HUNG សញ្ជាតិហុងកុង បង្កើតរោងចក្រកាត់ដេរសំលៀកបំពាក់នាំចេញ ៤៣

១០.០១.៩៧	ប្រកាសលេខ ០៥ ផក.ប្រក អនុញ្ញាតអោយលោក សុខ គីមហេង ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការឧស្សាហកម្មតូចផលិតទឹកកកដើម	៤៤
១០.០១.៩៧	ប្រកាសលេខ ០៦ ផក.ប្រក អនុញ្ញាតអោយលោក ជា អៀង ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការសិប្បកម្មផលិត នំប៉ុង សញ្ញា « ផ្កាត្របក ៥ »	៤៥
១០.០១.៩៧	ប្រកាសលេខ ០៧ ផក.ប្រក អនុញ្ញាតអោយលោក ឃាម សេង ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៦០ សេះ	៤៥
១០.០១.៩៧	ប្រកាសលេខ ០៨ ផក.ប្រក អនុញ្ញាតអោយលោក សុខ ញ៉ ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការឧស្សាហកម្មតូចផលិតទឹកកកដើម	៤៦
១០.០១.៩៧	ប្រកាសលេខ ០៩ ផក.ប្រក អនុញ្ញាតអោយលោក ពេញ សារ៉ូត ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៤០ សេះ	៤៦
១០.០១.៩៧	ប្រកាសលេខ ១០ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី ស៊ីវ ហុង ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងម៉ាស៊ីនផលិតទឹកកកដើម	៤៧
១៣.០១.៩៧	ប្រកាសលេខ ១១ ផក.ប្រក អនុញ្ញាតអោយលោក សុខ ឃឿន ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការឧស្សាហកម្មតូចផលិតស្រាស និង អាកុល	៤៧
១៣.០១.៩៧	ប្រកាសលេខ ១២ ផក.ប្រក អនុញ្ញាតអោយលោក ឈន ណារ័ត្ន ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ២៤ សេះ	៤៨

១៣.០១.៩៧	ប្រកាសលេខ ១៣ ផក.ប្រក អនុញ្ញាតអោយលោក ឈឹម សារិន ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការឧស្សាហកម្មតូចផលិតទឹកកកដើម	៤៨
១៣.០១.៩៧	ប្រកាសលេខ ១៤ ផក.ប្រក អនុញ្ញាតអោយលោក សាយ ស្រេង ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៨០ សេះ	៤៩
១៣.០១.៩៧	ប្រកាសលេខ ១៥ ផក.ប្រក អនុញ្ញាតអោយលោក ជៅ ជិនរ៉េត ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការឧស្សាហកម្មតូចផលិតទឹកកកដើម	៤៩
១៣.០១.៩៧	ប្រកាសលេខ ១៦ ផក.ប្រក អនុញ្ញាតអោយលោក ប៊ុន ឡេង ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការឧស្សាហកម្មតូចផលិតទឹកកកដើម	៥០
១៣.០១.៩៧	ប្រកាសលេខ ១៧ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី គង់ ឡាង ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការឡផលិតឥដ្ឋ ក្បឿង	៥០
១៣.០១.៩៧	ប្រកាសលេខ ១៨ ផក.ប្រក អនុញ្ញាតអោយលោក លឹម ខេង ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការឡផលិតឥដ្ឋ ក្បឿង	៥១
១៣.០១.៩៧	ប្រកាសលេខ ១៩ ផក.ប្រក អនុញ្ញាតអោយលោក ជួន វណ្ណៈ ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៦០ សេះ	៥១
១៣.០១.៩៧	ប្រកាសលេខ ២០ ផក.ប្រក អនុញ្ញាតអោយលោក សាយ ហ៊ុន ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៣០ សេះ	៥២

១៣.០១.៩៧ ប្រកាសលេខ ២១ ផក.ប្រក អនុញ្ញាតអោយលោក ហាក់ ស្រួយ ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការម៉ាស៊ីនផលិតទឹកកកដើម ៥២

១៣.០១.៩៧ ប្រកាសលេខ ២២ ផក.ប្រក អនុញ្ញាតអោយលោក ប៉ែន បូពា ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការឡផលិតឥដ្ឋ ក្បឿង ៥៣

១៣.០១.៩៧ ប្រកាសលេខ ២៣ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី មួន ចាន់នី ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការសិប្បកម្មផលិតសរសៃគុយទាវ ៥៣

១៣.០១.៩៧ ប្រកាសលេខ ២៤ ផក.ប្រក អនុញ្ញាតអោយលោក ខាន់ ឃិន ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ១៥ សេះ ៥៤

១៣.០១.៩៧ ប្រកាសលេខ ២៤ ផក.ប្រក អនុញ្ញាតអោយលោក យ៉ាំង លឿង ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៤៥ សេះ ៥៤

១៣.០១.៩៧ ប្រកាសលេខ ២៦ ផក.ប្រក អនុញ្ញាតអោយលោក យាំង លឿង ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៣១ សេះ ៥៥

១៣.០១.៩៧ ប្រកាសលេខ ២៧ ផក.ប្រក អនុញ្ញាតអោយលោក ទុយ ទីម ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៦៥ សេះ ៥៥

៥—ទីស្ដីការរដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ

ប្រកាស

១៥.១.៩៧ ប្រកាសលេខ ០១៨ ប្រក.កសក ស្តីពីការអនុញ្ញាតអោយបង្កើតរោងចក្រក្តារបន្ទះ និង កែច្នៃគ្រឿងសង្ហារឹម របស់ក្រុមហ៊ុន KING WOOD INDUSTY PTE LTD ៥៦

៦—និស្ស័យការរដ្ឋមន្ត្រីក្រសួងពត៌មាន

ប្រកាស

៩.០១.៩៧ ប្រកាសលេខ ០០៦/៩៧ ពម.ប្រក អនុញ្ញាតជូនលោក លឹម អៀវ បើកអាជីវកម្មរោងពុម្ពឈ្មោះ « លឹម អៀវ » ៥៩
៩.០១.៩៧ ប្រកាសលេខ ០០៧/៩៧ ពម.ប្រក អនុញ្ញាតអោយព្រឹត្តិប័ត្រឈ្មោះ « វិទ្យាស្ថានខ្មែរ » សំរាប់សហប្រតិបត្តិការ និង សន្តិភាព បោះពុម្ពចែកផ្សាយ ៦០
១៤.១.៩៧ ប្រកាសលេខ ០០៨/៩៧ ពម.ប្រក អនុញ្ញាតអោយសារពត៌មាន «ផ្កាយព្រឹក» បន្តការចេញផ្សាយរបស់ខ្លួនឡើងវិញ ៦២
១៥.១.៩៧ ប្រកាសលេខ ១១/៩៧ ពម.ប្រក អនុញ្ញាតជូនលោក ឆយ ជុនហ្វុន « J.H CHOI » បើកសេវាកម្មផ្សព្វផ្សាយពាណិជ្ជកម្មឈ្មោះ ASIA ADVERTISEMENT CO.LTD ៦៣
១៥.១.៩៧ ប្រកាសលេខ ០១២/៩៧ ពម.ប្រក ស្តីពីការតែងតាំងមន្ត្រីរាជការ ៦៤

៧—និស្ស័យការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

ប្រកាស

១៥.១.៩៧ ប្រកាសលេខ ៤៤ អយក.ប្រក ស្តីពីការប្តូរឈ្មោះសាលាបឋមសិក្សាតួងរ៉ុង មកជាសាលាបឋមសិក្សា «ហ៊ុន សែន មុនីវង្ស» ៦៥
១៥.១.៩៧ ប្រកាសលេខ ៤៦ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យទួលសំពៅ ក្នុងឃុំក្រាំងស្វាយ ខេត្តព្រៃវែង ៦៧

៨—ទីស្តីការរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ ជនបទ

ប្រកាស

១៣.១.៩៧ ប្រកាសលេខ ៦៤ ប្រក.អ.ជ.ប ស្តីពីការចាត់តាំងមន្ត្រីរាជការ លទ្ធកម្មសាធារណៈ គណៈកម្មាធិការកំណត់បុរេលក្ខណៈសម្បត្តិ វាយតម្លៃនិងប្រគល់កិច្ចសន្យា និង គណៈកម្មាធិការត្រួតពិនិត្យ ចំលងការលទ្ធកម្មប្រចាំក្រសួងអភិវឌ្ឍន៍ជនបទ ៦៨

៩—ទីស្តីការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

ប្រកាស

១៣.១.៩៧ ប្រកាសលេខ ០០៦ បទ.ប្រក ស្តីពីថ្លៃសន្ធនាទូរស័ព្ទអន្តរជាតិ ៧១

១៤.១.៩៧ ប្រកាសលេខ ០០៩ បទ.ប្រក ស្តីពីការតែងតាំងបន្ថែមសមាជិក គណៈកម្មការបច្ចេកទេសត្រួតពិនិត្យការងារជួសជុលកែលំអផ្លូវ ក្រោយពីការជីកកប់កាប្លិទូរស័ព្ទ ៧២

១០—ទីស្តីការក្រសួងធម្មការ និង សាសនា

ប្រកាស

១៤.១.៩៧ សេចក្តីសំរេចលេខ ០៥/៩៧ កធស អនុញ្ញាតជាគោលការណ៍ អោយបើកស្នាក់ការថ្វាយបង្គំព្រះត្រៃស្តនិកាយប្រេស ប៊ីតធីរាន នៃ ព្រះវិហារឈ្មោះ « ពួកជំនុំប្រេសប៊ីតធីរានភ្នំពេញ » នៅខណ្ឌទួលគោក រាជធានីភ្នំពេញ ៧៣

១៥.១.៩៧ ប្រកាសលេខ ០៦/៩៧ កធស ស្តីពីការតែងតាំងលោក ព្រុំ ស៊ូ ជា ប្រធានមន្ទីរធម្មការស្តីទីខេត្តព្រះវិហារ ៧៥

១៥.១.៩៧ សេចក្ដីសម្រេចលេខ ១៧/៩៧ កវស ស្ដីពីការអនុញ្ញាតអោយកសាង វត្តថ្មីឈ្មោះ « វត្តរង្សីបទុម លាចម្រាំ » នៅឃុំកំពង់ស្វាយ ស្រុកកៀនស្វាយ ខេត្តកណ្ដាល ៧៦

១១—រដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ

សេចក្ដីសម្រេច

១៣.១.៩៧ សេចក្ដីសម្រេចលេខ ០២១ សសរ មស ក្រខ ស្ដីពីការ បែងចែក និស្សិតចំនួន ២៦ នាក់ ដែលទើបបញ្ចប់ការសិក្សានៅ ប្រទេស ៧៧

I - ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

ព្រះរាជក្រឹត្យ នស រកត/០១៩៧/០៤

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស

អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- បានឃើញសំណើរបស់នាយករដ្ឋមន្ត្រីទាំង ២ និងសហរដ្ឋមន្ត្រីក្រសួងការពារជាតិ

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំងមុខដំណែងនិងតម្លើងឋានន្តរស័ក្តិនាយទាហានជាន់ខ្ពស់ក្នុងកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម ÷

ក_តែងតាំងផ្លាស់ប្តូរមុខដំណែងនិងតម្លើងឋានន្តរស័ក្តិជាឧត្តមសេនីយ៍ត្រី :

១_ លោកវរសេនីយ៍ឯក **សុខ សាវង** អត្តលេខ ០០០៣៥១ មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងក្រចេះ បច្ចុប្បន្នជាមេបញ្ជាការបញ្ជាការដ្ឋានកងទ័ពពិសេស អគ្គសេនាធិការ ។

២_ លោកវរសេនីយ៍ឯក **ទួន ម៉ុក** អត្តលេខ ០០០៣៧៥ មេបញ្ជាការ តំបន់ប្រតិបត្តិការសឹករងព្រះវិហារ បច្ចុប្បន្នជានាយរងការិយាល័យទី ៣ អគ្គសេនាធិការ

៣_ លោកវរសេនីយ៍ឯក **ឥត សារ៉ាត** អត្តលេខ ០០០៣៣៤ នាយករង ទីចាត់ការហ្វឹកហ្វឺន អគ្គសេនាធិការ បច្ចុប្បន្នជា នាយកទីចាត់ការហ្វឹកហ្វឺនអគ្គសេនាធិការ

៤_ លោកឧត្តមសេនីយឯក **គួច ម៉ិនឡើន** អត្តលេខ ០០០៤៧៥ នាយករង អធិការកិច្ច អគ្គមេបញ្ជាការ

៥_ លោកវរសេនីយ៍ឯក **ជ្រី ដេខ** អត្តលេខ ០០០៤២៨ មេបញ្ជាការរង កងពលធំលេខ ១ អគ្គសេនាធិការ បច្ចុប្បន្នជា មេបញ្ជាការ កងពលធំលេខ ១ អគ្គសេនាធិការ

ខ_តែងតាំងឋានន្តរស័ក្តិជា ឧត្តមសេនីយ៍ត្រី :

លោក **អ៊ុក ឡើន** មេបញ្ជាការអង្គរក្ស សម្តេចប្រធានរដ្ឋសភាជាតិ

មាត្រា ២ : នាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ រាជរដ្ឋាភិបាលកម្ពុជា និងជាសហអគ្គបញ្ជាការ កងយោធពលខេមរភូមិន្ទ ទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះអោយបានសំរេច ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ចាប់ពីថ្ងៃឡាយព្រះរាជហស្តលេខានេះតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៧

ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា

ព្រះហស្តលេខា

នរោត្តម សីហនុ

បានយកសេចក្តីសំរេចក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះរាជហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

បង្គំទូលថ្វាយ និង ជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រីទី ១ និង ទី ២

រដ្ឋមន្ត្រីក្រសួងការពារជាតិ

ហត្ថលេខា

ទៀ បាញ់ **នា ចាំរ៉ាត់**

ព្រះរាជក្រឹត្យ នស/រកត/០១៩៧/០៥

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស

អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- បានឃើញសំណើរបស់នាយករដ្ឋមន្ត្រីទាំង ២ និងសហរដ្ឋមន្ត្រីក្រសួងការពារជាតិ

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំងផ្លាស់ប្តូរមុខងារ នាយទាហានជាន់ខ្ពស់ ក្នុងកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម ÷

១_ លោកឧត្តមសេនីយ៍ត្រី **ខឹម ជាសាខឿន** អត្តលេខ ០០០១១៦ ពីមេបញ្ជាការរងយោធភូមិភាគពិសេស បច្ចុប្បន្នជាមេបញ្ជាការរងយោធភូមិភាគទី ៣ ។

២_ លោកឧត្តមសេនីយ៍ត្រី **ច្រាក់ សុវណ្ណា** អត្តលេខ ០០០០៩៦ ពីមេបញ្ជាការកងពលធំលេខ ១ បច្ចុប្បន្នជានាយរងការិយាល័យទី ៣ អគ្គសេនាធិការ ។

៣_ លោកឧត្តមសេនីយ៍ត្រី **ពូ សាម៉ុតឌី** អត្តលេខ ០០០១០៩ ពីមេបញ្ជាការ បញ្ជាការដ្ឋានទ័ពពិសេស បច្ចុប្បន្នជា នាយរងការិយាល័យទី ៣ អគ្គសេនាធិការ ។

៤_ លោកឧត្តមសេនីយ៍ត្រី **ហួត ឈាង** អត្តលេខ ០០០១៣៦ ពីនាយករងទីចាត់ការការងារគលយុទ្ធ អគ្គបញ្ជាការ បច្ចុប្បន្នជានាយរងការិយាល័យទី ៣ អគ្គសេនាធិការ ។

៥_ លោកឧត្តមសេនីយ៍ត្រី **ប្រាក់ សំអុល** អត្តលេខ ០០០២៧៦ ពីនាយរងការិយាល័យទី ៣ អគ្គសេនាធិការបច្ចុប្បន្នជានាយករងទីចាត់ការការងារគលយុទ្ធ អគ្គបញ្ជាការ ។

៦_ លោកឧត្តមសេនីយ៍ត្រី **អ៊ុង ស៊ាន** អត្តលេខ ០០០១១៣ នាយទីចាត់ការហ្វឹកហ្វឺនអគ្គសេនាធិការបច្ចុប្បន្នជានាយកបណ្ឌិតសភាយោធា កងយោធពលខេមរភូមិន្ទ ។

៧_ លោកឧត្តមសេនីយ៍ត្រី **ជុំ ហៀង** អត្តលេខ ០០០១៧២ ពីនាយសេនាធិការ កងនាវាចរបច្ចុប្បន្ន នាយករង ទីចាត់ការការងារគលយុទ្ធអគ្គបញ្ជាការ ។

មាត្រា ២ : នាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ រាជរដ្ឋាភិបាលកម្ពុជា និងជាសហអគ្គមេបញ្ជាការ កងយោធពលខេមរភូមិន្ទ ទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះអោយបានសំរេច ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ចាប់ពីថ្ងៃឡាយព្រះរាជហស្តលេខានេះតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៧
ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា
ព្រះហស្តលេខា
នរោត្តម សីហនុ

បានយកសេចក្តីសំរេចក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះរាជហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខា និងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

បង្គំទូលថ្វាយ និង ជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រីទី ១ និង ទី ២
រដ្ឋមន្ត្រីក្រសួងការពារជាតិ
ហត្ថលេខា

ទៀ បាញ់ **ឧា ចឺរ៉ាត់**

* * *

II - ទីស្តីការគណៈរដ្ឋមន្ត្រី

១_អនុក្រឹត្យ

រាជធានីភ្នំពេញ,ថ្ងៃទី ១០ ខែ មករា ឆ្នាំ ១៩៩៧

អនុក្រឹត្យលេខ ០១ អនក្រ.បក

ស្តីពីការផ្ទេរតំណែងនាន

រាជរដ្ឋាភិបាល

_បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

_បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះ មហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែង តាំងរាជរដ្ឋាភិបាលកម្ពុជា

_បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

_បានឃើញព្រះរាជក្រឹត្យ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តី ពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

_បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមនស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា

ឆ្នាំ ១៩៩៦

- បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ០១/ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រមលេខ នស/រកម/១២៩៥/០៧ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៥
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ.ហ ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ១៩៩៦ របស់រាជរដ្ឋាភិបាលស្តីពីការបែងចែកឥណទានផ្ទៃក្នុងជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៦
- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សំរេច

មាត្រា ១ : ត្រូវបានអនុញ្ញាតផ្ទេរឥណទានពីជំពូក ៤១ (ចំណាយឥតគ្រោងទុក) នៃថវិការដ្ឋចំនួន ២៥៣.៨៣០.០០០ រៀលគត់ (ពីររយហាសិបបីលានប្រាំបីរយសាមសិបពាន់រៀលគត់) បញ្ចូលទៅ ÷

- ជំពូក ១០ (បៀវត្សនិងប្រាក់បំណាច់) ចំនួន ៧៧.២៨០.០០០ រៀលគត់ (ចិតសិបប្រាំពីរលានពីររយប៉ែតសិបពាន់រៀលគត់) ។
- ជំពូក ៣១ (អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ចវប្បធម៌)ចំនួន ១៧៦.៥៥០.០០០ រៀលគត់ (មួយរយចិតសិបប្រាំមួយលានប្រាំរយហាសិបពាន់រៀលគត់) របស់ក្រសួងអប់រំយុវជន និងកីឡាផ្នែកឧត្តមសិក្សា ។

មាត្រា ២ : ត្រូវបានអនុញ្ញាតផ្ទេរឥណទានពីជំពូក ១១ (ចំណាយដំណើរការរដ្ឋបាលសំភារៈនិងជួសជុលតូច) ចំនួន ១៣៤.០០០.០០០ រៀលគត់ (មួយរយសាមសិបប្រាំបួនលានរៀលគត់) ទៅជំពូក ១០ (បៀវត្សនិងប្រាក់បំណាច់) របស់ក្រសួងអប់រំយុវជននិងកីឡាផ្នែកអប់រំ ។

មាត្រា ៣ : ឥណទានក្នុងមាត្រា ១ និងមាត្រា ២ ត្រូវបានអនុញ្ញាតអោយប្រើប្រាស់សំរាប់បំពេញបន្ថែមបៀវត្សអាហារូបករណ៍សិស្សនិស្សិត និងប្រាក់ម៉ោងបន្ថែមជូនសាស្ត្រាចារ្យ ។

មាត្រា ៤ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡា ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី១	នាយករដ្ឋមន្ត្រីទី២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ១៩៩៧

អនុក្រឹត្យលេខ ០២ អនក្រ.បក

ស្តីពីការប្រើប្រាស់គណនីឯកជនភាវូបនីយកម្ម

សហគ្រាសសាធារណៈ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៣
- បានឃើញច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រមលេខ ១១ នស ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤
- បានឃើញសេចក្តីប្រកាសរបស់រាជរដ្ឋាភិបាលលេខ ០១ សប្រក ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៤ ស្តីពីឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ

- បានឃើញអនុក្រឹត្យលេខ ៣៨ អនក្រ ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ១៩៩៥ ស្តីពីបែបបទ នៃឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី ៣១ កក្កដា ឆ្នាំ ១៩៩៥ ស្តីពីការ គ្រប់គ្រងលទ្ធកម្មសាធារណៈ
- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សំរេច

មាត្រា ១ : អនុញ្ញាតអោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រើប្រាស់គណនីឯកជនភាវូបនីយកម្មសហ គ្រាសសាធារណៈ ដែលត្រូវបានបង្កើតឡើងតាមមាត្រា ៨៣ នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការ គ្រប់គ្រងឆ្នាំ ១៩៩៥ លើមុខសញ្ញាជួសជុល និង សាងសង់ធារាសាស្ត្រក្នុងប្រព័ន្ធស្រោចស្រពកំពង់ទួល ទឹកថ្លាដែលមានទឹកប្រាក់ប្រមាណ ២.៤០០.០០០ USD (ពីរលានបួន រយពាន់ដុល្លារអាមេរិក) ។ ចំនួនទឹកប្រាក់ពិតប្រាកដ និងកំណត់ក្រោយពីធ្វើបែបបទលទ្ធកម្មសាធារណៈរួច ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នដែលពាក់ព័ន្ធមានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃ ឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី១	នាយករដ្ឋមន្ត្រីទី២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

២_ សេចក្តីសំរេច

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៧

សេចក្តីសំរេចលេខ ០៣ សសរ

ស្តីពីការរៀបចំកិច្ចប្រជុំនៃក្រុមពិគ្រោះយោបល់លើកទី ២

(Second Consultative Group Meeting)

និងកិច្ចប្រជុំគណៈកម្មាធិការអន្តរជាតិ ស្តីពីការស្តារកម្ពុជាលើកទី ៤

(4 th International Committee on the Reconstruction of Cambodia)

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ១០៩៤/៨៣/នស/រកត ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំនិងប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី ដែលត្រូវបានប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងតំរូវការចាំបាច់

សំរេច

ប្រការ ១ : ប្រគល់សិទ្ធិជូនឯកឧត្តម **គាត ឈន់** ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការនិតិសម្បទា និង អភិវឌ្ឍន៍ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាក្នុងការដឹកនាំនិងសំរបសំរួលការងារត្រៀមរៀបចំ សំរាប់កិច្ចប្រជុំនៃក្រុមពិគ្រោះយោបល់លើកទី ២ (Second Consultative Group Meeting) និងកិច្ចប្រជុំ នៃគណៈកម្មាធិការអន្តរជាតិ ស្តីពីការស្តារកម្ពុជាលើកទី ៤ (ICORC IV) ដែលនឹង ប្រព្រឹត្តទៅក្នុងឆ្នាំ ១៩៩៧ ។

ប្រការ ២ : ក្នុងក្របខ័ណ្ឌនៃការដឹកនាំនិងសំរបសំរួលការងារត្រៀមរៀបចំសំរាប់កិច្ចប្រជុំនេះ ឯកឧត្តម **គាត ឈន់** ត្រូវសហការជាមួយបណ្តាក្រសួងនិងស្ថាប័នទាំងអស់របស់រាជរដ្ឋាភិបាល និងមានសិទ្ធិអញ្ជើញមន្ត្រីជាន់ខ្ពស់អោយចូលរួមប្រជុំអន្តរក្រសួង និងមានសិទ្ធិចាត់ចែងធ្វើការពិគ្រោះយោបល់ជាមួយតំណាងប្រទេសនិងអង្គការអន្តរជាតិ អ្នកផ្តល់ជំនួយទ្វេភាគី ពហុភាគី ដើម្បីសំរបសំរួលការងារ និងដើម្បីរៀបចំពង្រាងឯកសារនានា ។

ប្រការ ៣ : ឯកឧត្តម **គាត ឈន់** ត្រូវរាយការណ៍ជាបន្តបន្ទាប់ថ្វាយ និង ជូនសម្តេចនាយករដ្ឋមន្ត្រីទី ២ អំពីលទ្ធផលនៃការងារដែលបានបំពេញ ហើយត្រូវរៀបចំឯកសារចាំបាច់ផ្សេងៗ សំរាប់កិច្ចប្រជុំលើកទី ២ នៃក្រុមពិគ្រោះយោបល់ ដើម្បីដាក់ជូននាយករដ្ឋមន្ត្រីពិនិត្យផ្តល់យោបល់ណែនាំ និងអនុម័តមុននឹងយកទៅប្រើប្រាស់ជាផ្លូវការ ។

ប្រការ ៤ : ក្នុងការបំពេញកិច្ចការនេះ ឯកឧត្តម **គាត ឈន់** ត្រូវប្រើប្រាស់របនាសម្ព័ន្ធរបស់គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា/ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (គ.ជ.ន/ក.អ.ក) សំរាប់ជាជំនួយការងារប្រចាំថ្ងៃ ។

ប្រការ ៥ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងនិងស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល និង ឯកឧត្តម **គាត ឈន់** ត្រូវអនុវត្តន៍សេចក្តីសំរេចនេះ ចាប់តាំងពីថ្ងៃឡាយព្រះហស្ថលេខានិងចុះហត្ថលេខានេះតទៅ ។

ប្រការ ៦ : សេចក្តីសំរេចនេះ មានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខារហូតដល់កិច្ចប្រជុំលើកទី ២ នៃក្រុមពិគ្រោះយោបល់បានប្រព្រឹត្តទៅចប់សព្វគ្រប់ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្ថលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

III - ការងារបណ្ដាក្រសួង

ប្រកាសអន្តរក្រសួង

១_ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
ទីស្ដីការរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ

រាជធានីភ្នំពេញ,ថ្ងៃទី ០៩ ខែ មករា ឆ្នាំ ១៩៩៧

ប្រកាសអន្តរក្រសួងលេខ ០០៤ សហវ មប្រក
ស្ដីពីការបង្កើតនិងកែងតាំងគ្នាក់ងារបើក
ផ្ដល់សំរាប់បើកបៀវត្សជូនមន្ត្រីរាជការ

នេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ

_បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

_យោងព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្ដម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

_យោងព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

_បានឃើញច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

_បានឃើញច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ ន.ស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣

- បានឃើញច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១ ន.ស ៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ០៤៤ ស.ហ.វ.ម.ប្រ.ក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការណែអនុវត្តន៍បទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញលិខិតលេខ ១១៥ ស.ហ.វ.ម ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការ អនុវត្តន៍បទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញតំរូវការចាំបាច់នៃការងារសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សំរេច

ប្រការ ១ : ប្រាក់បៀវត្សមន្ត្រីរាជការ នៃ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ នឹងត្រូវបើកផ្តល់តាមរយៈវជ្ជទេយ្យករដែលមានឈ្មោះថា ÷ « ភ្នាក់ងារបើកផ្តល់ » ។

ប្រការ ២ : - លោក **អ៊ុំ យស់** ត្រូវបានតែងតាំងជាភ្នាក់ងារបើកផ្តល់នៅនាយកដ្ឋាន គ្រឿងយន្តកសិកម្ម ។

- លោក **លឹម ហេង** ត្រូវបានតែងតាំងជាភ្នាក់ងារបើកផ្តល់នៅស្ថានីយ៍ស្រាវជ្រាវជលផល ។
- លោក **សោម សារិត** ត្រូវបានតែងតាំងជាភ្នាក់ងារបើកផ្តល់នៅមន្ទីរសុខាភិបាលចំការកៅស៊ូ ។

ប្រការ ៣ : អស់លោកដែលមានឈ្មោះក្នុងប្រការ ២ ខាងលើត្រូវបានអនុញ្ញាតអោយបើកគណនីប្រាក់បញ្ញើនៅរតនាគារជាតិ ដើម្បីទទួលមូលនិធិសំរាប់យកទៅបើកបៀវត្សជូនមន្ត្រីរាជការ ។

ប្រការ ៤ : បែបបទនៃការអនុវត្តន៍បើកផ្តល់បៀវត្ស នឹងត្រូវកំណត់ដោយសេចក្តីណែនាំជាក្រោយ ។

ប្រការ ៥ : ភ្នាក់ងារបើកផ្តល់ត្រូវទទួលខុសត្រូវផ្ទាល់ចំពោះប្រាក់កាស និងមូលនិធិដែលបានទទួលដើម្បីយកទៅធ្វើការបើកផ្តល់ជូនមន្ត្រីរាជការ ។

ប្រការ ៦ : សេចក្តីសំរេចទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍ ។

ប្រការ ៧ : ខុទ្ទកាល័យ មន្ទីរ នាយកដ្ឋានថវិកា នាយកដ្ឋានហិរញ្ញកិច្ច រតនាគារជាតិ ព្រមទាំងនាយកដ្ឋានពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុទាំងអស់ និង ក្រសួងកសិកម្មរុក្ខា ប្រមាញ់និងនេសាទ ព្រមទាំងអស់លោកដែលមានឈ្មោះនៅក្នុងប្រការ ២ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី
ទទួលបន្ទុកកិច្ចការនិតិសម្បទាន និង អភិវឌ្ឍន៍
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
ហត្ថលេខានិងត្រា
គាត ឈន់

រដ្ឋមន្ត្រីក្រសួងកសិកម្ម
រុក្ខាប្រមាញ់និងនេសាទ
រដ្ឋលេខាធិការ
ហត្ថលេខានិងត្រា
ឈាំ សុខ

* * *

២_ ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទីស្តីការរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

រាជធានីភ្នំពេញ,ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៧

ប្រកាសអន្តរក្រសួង

លេខ ០០៧ សហវ.មប្រក

ស្តីពីការបង្កើតនិងតែងតាំងភ្នាក់ងារបើកផ្តល់

សំរាប់បើកបៀវត្សជូនមន្ត្រីរាជការ

_បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

_យោងព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ

១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- យោងព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ ន.ស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១ ន.ស-៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ ស្តីពីបទបញ្ញត្តទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ០០៤ ស.ហ.វ.ម.ប្រ.ក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តន៍បទបញ្ញត្តទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញលិខិតលេខ ១១៥ ស.ហ.វ.ម ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការ អនុវត្តន៍បទបញ្ញត្តទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញតំរូវការចាំបាច់នៃការងារសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបច្ចុប្បន្ន

សំរេច

ប្រការ ១ : ប្រាក់បៀវត្សមន្ត្រីរាជការនៃក្រសួងមហាផ្ទៃផ្ទៃរដ្ឋបាល និងត្រូវបើកផ្តល់តាមរយៈរដ្ឋទេយ្យករដែលមានឈ្មោះថា : « ភ្នាក់ងារបើកផ្តល់ » ។

ប្រការ ២ : លោក**ម៉ន មង្គល** ត្រូវបានតែងតាំងជាភ្នាក់ងារបើកផ្តល់នៅក្រសួងមហាផ្ទៃ និងលោក **សុខ ឡើន** ត្រូវបានតែងតាំងជាភ្នាក់ងារបើកផ្តល់ជំនួស ។

ប្រការ ៣ : លោក **ម៉ន មង្គល** ត្រូវបានអនុញ្ញាតអោយបើកគណនីប្រាក់បញ្ញើនៅ រតនាគារជាតិ (ឬរតនាគារខេត្ត-ក្រុង) ដើម្បីទទួលមូលនិធិសំរាប់យកទៅបើកបៀវត្សជូនមន្ត្រីរាជការ ។

ប្រការ ៤ : បែបបទនៃការអនុវត្តន៍ បើកផ្តល់បៀវត្សនឹងត្រូវកំណត់ដោយសេចក្តីណែនាំជាក្រោយ ។

ប្រការ ៥ : ភ្នាក់ងារបើកផ្តល់ត្រូវទទួលខុសត្រូវផ្ទាល់ចំពោះប្រាក់កាស និងមូលនិធិដែលបានទទួលដើម្បីយកទៅធ្វើការបើកផ្តល់ជូនមន្ត្រីរាជការ ។

ប្រការ ៦ : សេចក្តីសំរេចទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៧ : ខុទ្ទកាល័យ មន្ទីរ នាយកដ្ឋានថវិកា នាយកដ្ឋានហិរញ្ញវត្ថុ រតនាគារជាតិព្រមទាំងនាយកដ្ឋានពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុទាំងអស និងក្រសួងមហាផ្ទៃ ព្រម ទាំងលោក **ម៉ន មង្គល** និងលោក **សុខ ជឿន** ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ	រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
ហត្ថលេខានិងត្រា	ហត្ថលេខានិងត្រា
ស ខេង **យូ ហុកគ្រី**	**គាត ឈន់**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៧

ប្រកាសអន្តរក្រសួងលេខ ០០៨ ស.ហ.វ.ម.ប្រ.ក
ស្តីពីការតែងតាំងគណនេយ្យករបុរេប្រទាន
នៅក្រសួងមហាផ្ទៃ « ផ្នែករដ្ឋបាល »

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-យោងព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ

១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- យោងព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ ន.ស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១ ន.ស ៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ០០៤ ស.ហ.វ.ម.ប្រ.ក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តន៍បទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញលិខិតលេខ ១១៥ ស.ហ.វ.ម ចុះថ្ងៃទី ១៦ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តន៍បទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញសារាចរណែនាំលេខ ០០៣ ស.ហ.វ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ស្តីពី ការប្រព្រឹត្តទៅនៃផ្នែកគណនេយ្យបុរេប្រទាន
- បានឃើញតំរូវការចាំបាច់នៃការងារសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សំរេច

ប្រការ ១ : - ត្រូវបានតែងតាំងលោក **ពិន សម្បត្តិ** ឋានៈមន្ត្រី អោយទទួលការងារបច្ចុប្បន្នជាភ្នាក់ងារគណនេយ្យ ករបុរេប្រទាននៅអមក្រសួងមហាផ្ទៃផ្នែករដ្ឋបាល ។
- ត្រូវបានតែងតាំងលោក **សួន សុគាល** ឋានៈមន្ត្រី អោយទទួលការងារជំនួសនៅពេលផ្នែកគណនេយ្យករបុរេប្រទានអវត្តមាន ។

ប្រការ ២ : ការតែងតាំងនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ១៩៩៧ នេះតទៅ ។

ប្រការ ៣ : ខុទ្ទកាល័យ មន្ទីរ រតនាគារជាតិ នាយកដ្ឋានព្រមទាំងអង្គភាពពាក់ព័ន្ធទាំងអស់ក្រោមឱវាទ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ ព្រមទាំងលោក

ពិន សម្បត្តិ និងលោក សួន សុគាព មានភារកិច្ចទទួលបន្ទុកអនុវត្ត ប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
ហត្ថលេខានិងត្រា
ស ខេង យូ ហុកគ្រី

ទេសរដ្ឋមន្ត្រី
ទទួលបន្ទុកកិច្ចការនិងសម្បទាននិងអភិវឌ្ឍន៍
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
ហត្ថលេខានិងត្រា
គាត ឈន់

* * *

៣_ ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ មករា ឆ្នាំ ១៩៩៧

ប្រកាសលេខ ០៥ ប្រក.សហវ.៣៥

ស្តីពីការបង្កើតការិយាល័យចាត់ចែង

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល

- បានឃើញច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/០១៩៦_១៨ ចុះថ្ងៃទី ២៤ ខែ ០២.នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៦
- បានឃើញច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០២ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ និងច្បាប់ស្ដីពីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០៨ នស ៩៤ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១ ន.ស ៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងច្បាប់ស្ដីពីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ជស.រកម.០៩៩៥.០១ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១១៩៥
- បានឃើញការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- តាមសំណើរបស់ប្រធាននាយកដ្ឋានពន្ធដារ

សំរេច

ប្រការ ១ : ត្រូវបានបានបង្កើតក្នុងនាយកដ្ឋានពន្ធដារ នូវការិយាល័យចាត់ចែង ។

ប្រការ ២ : ការិយាល័យនេះមានភារកិច្ច :

- សិក្សាលើការប្រព្រឹត្តិទៅ និងការងារចាត់ចែងនៃផ្នែក ការតាំងទីនិងតាមដានសកម្មភាពរបស់ផ្នែកទាំងនេះ
- ជួយអោយដំណើរការនូវវិធានការច្បាប់ដោយចូលរួមរៀបចំឯកសារបោះពុម្ព និង ចូលរួមក្នុងការបង្កើត ឬ ធ្វើសនិទានកម្មបែបបទរដ្ឋបាលទាំងឡាយ
- ប្រមូលផ្ដុំរាល់ស្ថិតិទាក់ទងដល់មូលដ្ឋានកំណត់ពន្ធ
- រៀងរាល់ឆ្នាំការិយាល័យនេះ ធ្វើសំយោគលើរាល់ស្ថានភាពស្ថិតិទាក់ទងដល់មូលដ្ឋានកំណត់ពន្ធ ត្រួតពិនិត្យសារពើពន្ធ ប្រមូលពន្ធ វិវាទពន្ធដារ និង កសាងតារាងរបាយការណ៍សរុបអំពីស្ថិតិលើគ្រប់ផ្នែកនៃនាយកដ្ឋានពន្ធដារ

- គ្រប់គ្រងមជ្ឈមណ្ឌលឯកសារនាយកដ្ឋានពន្ធដារនិងបង្កើតបញ្ជីសំរាប់កត់ត្រារាល់ឯកសាររដ្ឋបាល (កំណត់ចាត់ចែង ប្រកាសណែនាំ បទបញ្ជា ច្បាប់ ហិរញ្ញវត្ថុសេចក្តីសំរេចរបស់ក្រសួង សារាចរផ្សេងៗ ។ល។)
- ទទួលបន្ទុកលើរាល់ទំនាក់ទំនង[illegible]ជាពិសេសជាមួយនិងវិជ្ជាជីវៈគណនេយ្យ និង ចូលរួមក្នុងការប្រជុំជាមួយអង្គការវិជ្ជាជីវៈទាំងឡាយ(សភាពាណិជ្ជកម្ម)
- ធានាធ្វើការផ្សព្វផ្សាយរាល់ឯកសារសំរាប់ផ្នែកទាំងឡាយ
- ទទួលបន្ទុកកសាងនិងផ្សព្វផ្សាយរាល់សេចក្តីកំណត់ និវេទន៍ កម្រងសៀវភៅ កូនសៀវភៅតូចៗ និងឯកសារផ្សេងៗ សំរាប់ផ្តល់ពត៌មានដល់ផ្នែក និងដល់សាធារណជន ។

ប្រការ ៣ :អគ្គនាយក នាយកខុទ្ទកាល័យ ប្រធានមន្ទីរ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានពន្ធដារ និងអង្គភាពដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ។

ហត្ថលេខានិងត្រា

គាត ឈន់

* * *

៤— ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ប្រកាស

ប្រកាសលេខ ០៣ ឧក.ប្រក ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយក្រុមហ៊ុន ខូលីធី តេក្សស្ទីល ខូអែលធីឌី (QUALITY TEXTILES Co.,LTD) តំណាងដោយលោក SEOW FUI CHEONG សញ្ជាតិម៉ាឡេស៊ី ភេទប្រុស អាយុ ៥៣ ឆ្នាំ អាស័យដ្ឋាន N23 JALAN BUNGARAYA. 75100 MELAKA. MALAYSIA កាន់លិខិតឆ្លងដែនលេខ A 5922907 ចុះថ្ងៃទី ០៩–០២–៩៣ «បង្កើត រោងចក្រកាត់ដេរ សំលៀក

បំពាក់នាំចេញ » ដែលមានឈ្មោះថា «រោងចក្រកាត់ដេរ សំលៀកបំពាក់ ខូលីធី តេក្សស៊ីល ទី ២ «មានទីតាំងស្ថិតនៅអតីតរោងចក្រយន្តសាស្ត្រ ទី ៧ ឡូត៍លេខ ១៦៧១ ផ្លូវជាតិលេខ ២ សង្កាត់ចាក់អង្រែក្រោម ខ័ណ្ឌមានជ័យ រាជធានី ភ្នំពេញ ។

ប្រការ ២ : ការបង្កើតរោងចក្រនេះ ត្រូវធ្វើទៅតាមប្លង់ និង គំរោងសិក្សាលទ្ធភាពបង្កើតរោងចក្រកាត់ ដេរសំលៀកបំពាក់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ៣ : ក្នុងកិច្ចដំណើរការក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាការពារបរិស្ថាន និងគុណភាពផលិតផល ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល អំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ។

ប្រការ ៤ : រោងចក្រនេះត្រូវបានអនុញ្ញាតអោយនូវផលិតផល «សំលៀកបំពាក់ » ទៅតាមគំរូដែលតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៥ : ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរ និងប្រការណាមួយដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ០៤ ឧក.ប្រក. ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយក្រុមហ៊ុន ថាយ វ៉ាហ្គាម៉ែនម៉េញ ហ្វាក់ឆឺរ៉ុង(កម្ពុជា)(TAI WAH GARMENT MANUFACTURING CAMBODIA Co . LTD) តំណាងដោយ លោក CHONG CHOK HUNG សញ្ជាតិហុងកុង ភេទប្រុស អាយុ ៥៩ ឆ្នាំ អាស័យដ្ឋាន FLAT C4/F WING HING IND BLDG CASTLE PEAK ROAD KOWLOON HONGKONG កាន់លិខិតឆ្លងដែនលេខ B344517 (3) ចុះថ្ងៃទី ២៣/០៨/៩៣ បង្កើតរោងចក្រកាត់ដេរសំលៀកបំពាក់នាំចេញ ដែលមានឈ្មោះថា " រោងចក្រកាត់ដេរ ថាយ វ៉ាហ្គាម៉ែនម៉េញ ហ្វាក់ឆឺរ៉ុង (កម្ពុជា) មានទីតាំងស្ថិតនៅ អតីតរោងចក្រថ្នសជុល កង់រថយន្ត SKP ផ្លូវ ៦៨ សង្កាត់ស្រះចក ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ ។

ប្រការ ២ : ការបង្កើតរោងចក្រនេះ ត្រូវធ្វើទៅតាមប្លង់ និងគំរោងសិក្សាលទ្ធភាពបង្កើតរោងចក្រកាត់ដេរសំលៀកបំពាក់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល ។

ប្រការ ៣ : ក្នុងកិច្ចដំណើរការក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាការពារបរិស្ថាន និងគុណភាពផលិតផល ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែជូនក្រសួងឧស្សាហកម្ម រ៉ែនិងថាមពលអំពីស្ថានភាពផលិតផលរបស់រោងចក្រ ។

ប្រការ ៤ : រោងចក្រនេះត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផល " សំលៀកបំពាក់ " ទៅតាមគំរូ ដែលតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល ។

ប្រការ ៥ : ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសចូនចូរនឹងប្រការណាមួយដែលបានចែងខាងលើប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ០៥ ឧក.ប្រក. ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **សុខ គីមហេង** ជនជាតិខ្មែរ សញ្ញាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ៣២៥៨០៩ ភព.ចុះថ្ងៃទី ១៦/១១/៩១ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ១០៣ ផ្លូវលេខ ១៤៦ សង្កាត់ ផ្សារដេប៉ូទី២ ខ័ណ្ឌទួលគោករាជធានីភ្នំពេញ បន្តដំណើរការឧស្សាហកម្មតូច ផលិតទឹកកកដើមនៅក្នុង ទីតាំងផ្ទះលេខ ១០៣ ផ្លូវលេខ ១៤៦ សង្កាត់ផ្សារដេប៉ូទី២ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ។

ប្រការ ២ : ប្រកាសនេះ មានតំលៃក្នុងរយៈពេល ៣ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ផលិតផលគ្មានគុណភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូត វិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ០៦ ឧក.ប្រក. ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **ជា អឿន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០០៩៧៨៨ ភព.ចុះថ្ងៃទី៩/១២/៩៤ អាស័យដ្ឋានបច្ចុប្បន្ន ដីឡូត៍លេខ៥ ផ្លូវលេខ ២៥៩ សង្កាត់ទឹកល្អក់ទី២ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ បន្តដំណើរការសិប្បកម្មផលិតនំប៉័ងសញ្ញា " ផ្កាត្របែក៥ " នៅក្នុងទីតាំងដីឡូត៍លេខ ៥ ផ្លូវលេខ ២៥៩ សង្កាត់ទឹកល្អក់ទី២ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ។

ប្រការ ២ : ប្រកាសនេះ មានតំលៃក្នុងរយៈពេល ៣ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផលគ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ០៧ ឧក.ប្រក. ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **ឃាម សេខ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៩០៥៥៧ ពវ.ចុះថ្ងៃទី ០៥/៤/៨៨ អាស័យដ្ឋានបច្ចុប្បន្នភូមិបាបោង ឃុំបាបោង ស្រុកពាមរក៍ ខេត្ត ព្រៃវែង បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៦០សេះ នៅក្នុងទីតាំងភូមិព្រែកក្បាយ "ក" ស្រុក ពាមរក៍ខេត្តព្រៃវែង ។

ប្រការ ២ : លោក **ឃាម សេខ** ត្រូវបន្តដំណើរការផលិតកម្ម-អាជីវកម្មលើទីតាំងដូចបានកំណត់ក្នុងប្លង់ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ភាគរយ ។

ប្រការ ៣ : ប្រកាសនេះ មានតំលៃក្នុងរយៈពេល ៣ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ០៨ ផក.ប្រក. ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **សុខ ញ៉ូ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២៨៧០៧៤ ភព.ចុះថ្ងៃទី ០៣/៧/៨៩ អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ ១៥៤០ ផ្លូវជាតិលេខ ៥ សង្កាត់ឫស្សី កែវ ខ័ណ្ឌឫស្សីកែវ រាជធានីភ្នំពេញ បន្តដំណើរការឧស្សាហកម្មតូច ផលិតទឹកកកដើម នៅក្នុងទីតាំងផ្ទះ សង់ថ្មី ផ្លូវជាតិលេខ ៥ សង្កាត់ឫស្សីកែវ ខ័ណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

ប្រការ ២ : ប្រកាសនេះ មានតំលៃក្នុងរយៈពេល ៣ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ផលិតផលគ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ០៩ ផក.ប្រក. ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **ពេញ សារ៉ុត** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០០៧២៨៧ ពវ.ចុះថ្ងៃទី ១៤/៥/៨៦ អាស័យដ្ឋានបច្ចុប្បន្នក្រុមទី៣ ភូមិឧត្តម ឃុំព្រែកខ្សាយ "ក" ស្រុកពាមរក៍ ខេត្តព្រៃវែង បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៤០សេះ នៅក្នុងទីតាំងក្រុមទី៣ ភូមិឧត្តម ឃុំព្រែកខ្សាយ "ក" ស្រុកពាមរក៍ ខេត្តព្រៃវែង ។

ប្រការ ២ : លោក **ពេញ សារ៉ុត** ត្រូវបន្តដំណើរការផលិតកម្ម-អាជីវកម្មលើទីតាំងដូចបានកំណត់ក្នុងប្រការ១ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះ មានតំលៃក្នុងរយៈពេល ៣ឆ្នាំ ។ ផុតកំណត់ពេលនេះម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រកាសលេខ ១០ ឧក.ប្រក. ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **ស៊ុំ ហួន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ៣៣៨៩៦៤ ពវ.ចុះថ្ងៃទី ០៨/០២/៩១ អាស័យដ្ឋានបច្ចុប្បន្ន ភូមិ ៤ ឃុំព្រែកខ្សាយ "ក" ស្រុកពាមរក៍ ខេត្តព្រៃវែង បន្តដំណើរការរោងម៉ាស៊ីនផលិតទឹកកកដើមនៅក្នុងទីតាំង ភូមិ ៥ ឃុំព្រែកខ្សាយ "ខ" ស្រុកពាមរក៍ ខេត្តព្រៃវែង ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល ៣ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ផលិតផលគ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ១១ ឧក.ប្រក. ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **សុខ ឃឿន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ៣០៩៣៣២ កណ.ចុះថ្ងៃទី ២០/១២/៩១ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៥១២ ផ្លូវជាតិលេខ ៥ ក្រុមទី៧ ភូមិស្ពានខ្ពស់ សង្កាត់គីឡូម៉ែត្រ បន្តដំណើរការឧស្សាហកម្មតូចផលិតស្រាសនិងអាល់កុល យី ហោ " **សឿ ម្លូន ខ្វន** " សញ្ញា " គោនិងផែនដី " នៅក្នុងទីតាំងផ្លូវជាតិលេខ ១៥ ភូមិព្រែក ខ្សាយ ឃុំព្រែកខ្សាយ "ក" ស្រុកពាមរក៍ ខេត្តព្រៃវែង ។

ប្រការ ២ : ប្រកាសនេះ មានតំលៃក្នុងរយៈពេល ៣ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ផលិតផលគ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ១២ ឧក.ប្រក. ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយរោងម៉ាស៊ីនកិនស្រូវដែលមានលោក **ឈន ឈារ័ត្ន** ជនជាតិខ្មែរ សញ្ញាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ០៨៩០៦២ បប.ចុះថ្ងៃទី ២៣.៣.៨៨ ជាប្រធាន អាស័យដ្ឋាន បច្ចុប្បន្ន ភូមិប្រឡាយស្ពោ ឃុំតាលាស់ ស្រុកមោងឫស្សី ខេត្តបាត់ដំបង បើកដំណើរការផលិតកម្ម ដោយប្រើម៉ាស៊ីនកំលាំង ២៤សេះ នៅក្នុងទីតាំង ភូមិ ប្រឡាយស្ពោ ឃុំតាលាស់ ស្រុកមោងឫស្សី ខេត្តបាត់ដំបង

ប្រការ ២ : លោក **ឈន ឈារ័ត្ន** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម-អាជីវកម្មលើទីតាំង ដូចបានកំណត់ ក្នុងប្លង់ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិច បំផុត ៦៥ភាគរយ ។

ប្រការ ៣ : ប្រកាសនេះ មានតំលៃក្នុងរយៈពេល ៣ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ១៣ ឧក.ប្រក. ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **ឈឹម សារិន** ជនជាតិខ្មែរ សញ្ញាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០២៩៧៨០ កណ.ចុះថ្ងៃទី ២៣/៧/៨៩ អាស័យដ្ឋានបច្ចុប្បន្ន ភូមិទួលត្នោត ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្តាល បន្តដំណើរការរោងម៉ាស៊ីនផលិតទឹកកកដើម នៅក្នុងទីតាំង ភូមិទួលត្នោត ឃុំគគីរ ស្រុកកៀនស្វាយខេត្តកណ្តាល ។

ប្រការ ២ : ប្រកាសនេះ មានតំលៃក្នុងរយៈពេល ៣ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ផលិតផលគ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្កអោយ

មានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណង ឡើយ ។

* * *

ប្រកាសលេខ ១៤ ឧក.ប្រក. ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **សាយ ស្រេង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ២៤៣៨៦៦ ភព.ចុះថ្ងៃទី ២៦/៦/៨១ អាស័យដ្ឋានបច្ចុប្បន្ន សង្កាត់ទឹកល្អក់ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៨០សេះ នៅក្នុងទីតាំងភូមិ ត្រពាំងស្វាយ ឃុំ ក្រាំងម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្តាល ។

ប្រការ ២ : លោក **សាយ ស្រេង** ត្រូវបន្តដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្រការ១ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ភាគរយ ។

ប្រការ ៣ : ប្រកាសនេះ មានតំលៃក្នុងរយៈពេល ៣ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់មានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណង ឡើយ ។

* * *

ប្រកាសលេខ ១៥ ឧក.ប្រក. ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **ដៅ ខិនរ៉ែត** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២៥៨៦៦៥ បប.ចុះថ្ងៃទី ២៤/៧/៩២ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ១៥១ ក្រុមទី ៩ មណ្ឌល ១ សង្កាត់ផ្សារកណ្តាល ២ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ បើកដំណើរការឧស្សាហកម្មតូច ផលិតទឹក កកដើម នៅក្នុងទីតាំង ក្រុមទី ៤ មណ្ឌល ៤ សង្កាត់លេខ ៤ ខ័ណ្ឌមិត្តភាព ក្រុងព្រះសីហនុ ។

ប្រការ ២ : ប្រកាសនេះ មានតំលៃក្នុងរយៈពេល ៣ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណី

ប្រព្រឹត្តល្មើសច្បាប់ផលិតផលគ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូត វិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ១៦ ឧក.ប្រក. ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយសហគ្រាសខ្នាតតូចផលិតទឹកកកដើមដែលមានលោក **ម៉ុន ឡេង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ០៩៣៥៦០ ភព. ចុះថ្ងៃទី ២០/១១/៨៩ ជាប្រធាន អាស័យដ្ឋានបច្ចុប្បន្នក្រុមទី ២៦ ភូមិ ១ សង្កាត់ព្រះពន្លា ទីរួមខេត្តបន្ទាយមានជ័យខេត្តបន្ទាយមានជ័យបន្តដំណើរការផលិតកម្មនៅក្នុងទីតាំងក្រុមទី ១ ភូមិរតនៈ ឃុំរតនៈ ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង ។

ប្រការ ២ : ប្រកាសនេះ មានតំលៃក្នុងរយៈពេល ៣ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មាន សំណងឡើយ ។

* * *

ប្រកាសលេខ ១៧ ឧក.ប្រក. ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **គង់ ឡាង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ៣១៨៨៣៥ ភព. ចុះថ្ងៃទី ១៤/១២/៩១ អាស័យដ្ឋានបច្ចុប្បន្ន ភូមិគំណាក់សង្កែ ឃុំព្រែកកំពឹស ស្រុក កណ្តាលស្ទឹង ខេត្តកណ្តាល បន្តដំណើរការឡផលិតឥដ្ឋ-ក្បឿង នៅក្នុងទីតាំង ភូមិគំណាក់សង្កែ ឃុំព្រែក កំពឹស ស្រុក កណ្តាលស្ទឹង ខេត្តកណ្តាល ។

ប្រការ ២ : ប្រកាសនេះ មានតំលៃក្នុងរយៈពេល ៣ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថានប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ១៨ ផក.ប្រក. ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយសិប្បកម្មផលិតឥដ្ឋ-ក្បឿង ដែលមានលោក **លឹម ខេង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ០៩១០២១ ភព. ចុះថ្ងៃទី ២៦/៣/៨៥ ជាប្រធាន អាស័យ ដ្ឋានបច្ចុប្បន្នភូមិ ក្តីចាស់ ឃុំចាក់ខែង ស្រុកមុខកំពូល ខេត្តកណ្តាល បន្តដំណើរការផលិតកម្មនៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : ប្រកាសនេះ មានតំលៃក្នុងរយ:ពេល ៣ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ឬបង្ក អោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ១៩ ផក.ប្រក. ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **ជួន វណ្ណៈ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២៧៣៩៩៦ កណ.ចុះថ្ងៃទី ១២/៦/៩០ អាស័យដ្ឋានបច្ចុប្បន្នភូមិក្រពើហារ ឃុំព្រែកឫស្សី ស្រុកតាខ្មៅ ខេត្តកណ្តាល បន្តដំណើរការរោង ម៉ាស៊ីនកិនស្រូវកំលាំង ៦០សេះ នៅក្នុងទីតាំងភូមិក្រពើហារ ឃុំព្រែកឫស្សី ស្រុកតាខ្មៅ ខេត្តកណ្តាល ។

ប្រការ ២ : លោក **ជួន វណ្ណៈ** ត្រូវបន្តដំណើរការផលិតកម្មអាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្រការ១ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះ មានតំលៃក្នុងរយ:ពេល ៣ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬបង្កអោយ មានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ២០ ឧក.ប្រក. ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **សាយ ហ៊ិន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២៨៨១៩៥ កណ. ចុះថ្ងៃទី ០២/៨/៨៩ អាស័យដ្ឋានបច្ចុប្បន្ន ភូមិលេខ ៤ ឃុំស្វាយរលំ ស្រុកស្អាង ខេត្តកណ្តាល បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៣០សេះ នៅក្នុងទីតាំង ភូមិលេខ ៤ ឃុំស្វាយរលំ ស្រុកស្អាង ខេត្តកណ្តាល ។

ប្រការ ២ : លោក **សាយ ហ៊ិន** ត្រូវបន្តដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះ មានតំលៃក្នុងរយៈពេល ៣ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ផលិតផលគ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូត វិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ២១ ឧក.ប្រក. ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **ហាក់ ស្រួយ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៦០៩០៤ កណ. ចុះថ្ងៃទី ១៧/១២/៨៦ អាស័យដ្ឋានបច្ចុប្បន្ន ភូមិ កំពង់ចំលង ឃុំព្រែកទម្លាប់ ស្រុកលើកដែក ខេត្តកណ្តាលបន្តដំណើរការរោងម៉ាស៊ីនផលិតទឹកកកដើម នៅក្នុងទីតាំងភូមិអំពិលទឹក ឃុំកំពង់ភ្នំ ស្រុកលើកដែក ខេត្តកណ្តាល ។

ប្រការ ២ : ប្រកាសនេះ មានតំលៃក្នុងរយៈពេល ៣ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ផលិតផលគ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូត វិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ២២ ឧក.ប្រក. ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **ម៉ែន ឌូឆាវ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ៣០០០៨៤ ភព.ចុះថ្ងៃទី ២៥/១១/៩០ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៣៩ អឺ១ ផ្លូវលេខ ១៧៨ ក្រុមទី ២៨ សង្កាត់ជ័យជំនះ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ បន្តដំណើរការឡផលិតឥដ្ឋ-ក្បឿង នៅក្នុងទីតាំងភូមិ ជ្រោយអំពិល ឃុំក្បាលកោះ ស្រុកកៀនស្វាយ ខេត្តកណ្តាល ។

ប្រការ ២ : ប្រកាសនេះ មានតំលៃក្នុងរយៈពេល ៣ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ឬបង្កអោយ មានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ២៣ ឧក.ប្រក. ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **មួន ចាន់នី** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់លិខិតបញ្ជាក់លេខ ៣៤៧/៩៦កមស.អក ចុះថ្ងៃទី ១១/១២/៩៦ អាស័យដ្ឋានបច្ចុប្បន្ន ក្រុមទី៩ ភូមិសំរោងក្នុង ឃុំសំរោងក្នុង ស្រុកឯកភ្នំ ខេត្តបាត់ដំបង បើកដំណើរការសិប្បកម្មផលិតសរសៃគុយទាវ នៅក្នុងទីតាំងក្រុមទី៩ ភូមិ សំរោងក្នុង ឃុំសំរោងក្នុងស្រុកឯកភ្នំ ខេត្តបាត់ដំបង ។

ប្រការ ២ : ប្រកាសនេះ មានតំលៃក្នុងរយៈពេល ៣ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ផលិតផលគ្មានគុណភាព ប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូត វិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ២៤ ឧក.ប្រក. ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **ខាត់ ឃិន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២១៨១៦២ កណ. ចុះថ្ងៃទី ២៥/១១/៨៨ អាស័យដ្ឋានបច្ចុប្បន្ន ភូមិស្វាយព្រៃ ឃុំកណ្តោក ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ១៥សេះ នៅក្នុងទីតាំងភូមិ ស្វាយព្រៃ ឃុំកណ្តោក ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។

ប្រការ ២ : លោក **ខាត់ ឃិន** ត្រូវបន្តដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ភាគរយ ។

ប្រការ ៣ : ប្រកាសនេះ មានតំលៃក្នុងរយៈពេល ៣ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬបង្កអោយ មានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ២៥ ឧក.ប្រក. ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **ឃុាំង លឿង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ១៨១៤១៨ បប.ចុះថ្ងៃទី ២៣/០១/៩០ អាស័យដ្ឋានបច្ចុប្បន្ន ក្រុមទី១២ ភូមិក្ដុល ឃុំក្ដុល ស្រុក ស្វាយប៉ោ ខេត្តបាត់ដំបង បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៤៥សេះ នៅក្នុងទីតាំង ក្រុមទី១៣ ភូមិពពាយខែ ឃុំអូរតាគី ស្រុកបាត់ដំបង ខេត្តបាត់ដំបង ។

ប្រការ ២ : លោក **ឃុាំង លឿង** ត្រូវបន្តដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ភាគរយ ។

ប្រការ ៣ : ប្រកាសនេះ មានតំលៃក្នុងរយៈពេល ៣ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្ត

ល្មើសច្បាប់ ឬបង្ក អោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ២៦ ឧក.ប្រក. ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយលោក **ឃឿន ឈឿន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ១៨១៤១៨ បប.ចុះថ្ងៃទី ២៣/០១/៩០ អាស័យដ្ឋានបច្ចុប្បន្ន ក្រុមទី១២ ភូមិក្តុល ឃុំក្តុល ស្រុក ស្វាយចេា ខេត្តបាត់ដំបង បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៣១សេះ នៅក្នុងទីតាំង ក្រុមទី៨ ភូមិតាកុយ ឃុំក្តុល ស្រុកស្វាយចេា ខេត្តបាត់ដំបង ។

ប្រការ ២ : លោក **ឃឿន ឈឿន** ត្រូវបន្តដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ភាគរយ ។

ប្រការ ៣ : ប្រកាសនេះ មានតំលៃក្នុងរយៈពេល ៣ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬបង្កអោយ មានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ២៧ ឧក.ប្រក. ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយរោងម៉ាស៊ីនកិនស្រូវដែលមានលោក **ឌុយ ឌឹម** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ០៦៦៣១៩ បប.ចុះថ្ងៃទី ២១/៨/៨៧ ជាប្រធាន អាស័យដ្ឋានបច្ចុប្បន្ន ក្រុមទី១២ ភូមិអូរខ្ចាយ ឃុំអូរដំបង១ ស្រុកសង្កែ ខេត្តបាត់ដំបង បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៦៥សេះ នៅក្នុងទីតាំង ក្រុមទី១២ ភូមិអូរខ្ចាយ ឃុំអូរដំបង១ ស្រុកសង្កែ ខេត្តបាត់ដំបង ។

ប្រការ ២ : លោក **ឌុយ ឌឹម** ត្រូវបន្តដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដូចបានកំណត់ក្នុងប្លង់ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត

៦៥ភាគរយ ។

ប្រការ ៣ : ប្រកាសនេះ មានតំលៃក្នុងរយៈពេល ៣ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្ត ល្មើសច្បាប់ ឬបង្ក អោយមានការបំពុលដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូត វិញដោយគ្មានសំណងឡើយ ។

ជ. រដ្ឋមន្ត្រី
រដ្ឋលេខាធិការ
ហត្ថលេខានិងត្រា
អ៊ុក ឡាំង

* * *

៥_ នីស្តីការរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

ប្រកាស

ភ្នំពេញថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៧

ប្រកាសលេខ ០១៨ ប្រក.កសក

ការអនុញ្ញាតអោយបង្កើតរោងចក្រក្តារបន្ទះនិងកែ ច្នៃឈ្មើងសង្ហារឹមរបស់ក្រុមហ៊ុន KING WOOD INDUSTRY PTE . LTD

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦

- បានឃើញក្រឹត្យច្បាប់លេខ ៣៥ ក្រច ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ១៩៨៨ ស្តីពីការគ្រប់គ្រងវិស័យព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់ក្រសួងកសិកម្ម
- បានឃើញប្រកាសលេខ ០០៩២ ប្រក.កសក.ម ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ១៩៨៩ របស់ក្រសួងកសិកម្ម ស្តីពីការបង្កើតនិងគ្រប់គ្រងរោងចក្រអារឈើ រោងចក្រកែច្នៃឈើរោងអារឈើ រោងជាងឈើ សិប្បកម្មប្រើប្រាស់វត្ថុធាតុដើមជាផល_អនុផលព្រៃឈើរបស់រដ្ឋ រដ្ឋចំរុះឯកជន សមូសហភាពនិងឯកក្នុងទូទាំងរដ្ឋកម្ពុជា ។
- បានឃើញកិច្ចព្រមព្រៀងវិនិយោគទុនធ្វើអាជីវកម្ម ព្រៃសម្បទានលើផ្ទៃដី ៦៣.១០០ហិកតា នៅក្នុងខេត្តក្រចេះរវាងរាជរដ្ឋាភិបាលនៃ ព្រះរាជាណាចក្រកម្ពុជា និងក្រុមហ៊ុន KING WOOD INDUSTRY PTE . LTD ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ១៩៩៥
- បានឃើញកិច្ចព្រមព្រៀងវិនិយោគធ្វើអាជីវកម្មព្រៃសម្បទានលើផ្ទៃដី ១៤៦.៣០០ ហិកតា នៅក្នុងខេត្តសៀមរាបនិងព្រះវិហារ រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងក្រុម ហ៊ុន KING WOOD INDUSTRY PTE . LTD ចុះថ្ងៃទី ខែ ឆ្នាំ ១៩៩៦
- បានឃើញមតិយល់ព្រមរបស់អភិបាលខេត្តកណ្តាលលេខ ១១១ លអ ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ១៩៩៥ លើពាក្យស្នើសុំបង្កើតរោងចក្រក្តារបន្ទះ និងកែច្នៃគ្រឿងសង្ហារឹមរបស់ ឈ្មោះ LIA - CHUN HUA ប្រធានក្រុមហ៊ុន KING WOOD INDUSTRY PTE . LTD ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ១៩៩៥
- តាមសំណើរបស់ប្រធាននាយកដ្ឋានរុក្ខាប្រមាញ់

សំរេច

ប្រការ ១ : អនុញ្ញាតអោយក្រុមហ៊ុន KING WOOD INDUSTRY PTE . LTD មានទីស្នាក់ការនៅផ្ទះលេខ ៦០ ផ្លូវលេខ ៣១០ សង្កាត់បឹងកេងកងទី ១ ខ័ណ្ឌចំការមនរាជធានីភ្នំពេញ បង្កើតរោងចក្រក្តារបន្ទះ និងកែច្នៃគ្រឿង សង្ហារឹមមួយកន្លែងដែលមាន :

–ទីតាំងនៅភូមិកណ្ដាល ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្ដាល
–ម៉ាស៊ីន ៤ ខ្សែសង្វាក់ផលិតកម្ម
–សមត្ថភាពផលិតក្នុង ១ ខែ ១០.០០០ ម៉ែត្រគ្រីគុណ គិតជាឈើមូល

ប្រការ ២ : សាមីជនដែលបានទទួលការអនុញ្ញាតត្រូវប្រតិបត្តិតាមល័ក្ខខ័ណ្ឌនៃ បទបញ្ញាខាងក្រោម :

ក – សំណង់រោងចក្រក្ដារបន្ទះ និងកែច្នៃគ្រឿងសង្ហារឹមត្រូវតាំងនៅកន្លែងដែលមានតាមគំរូប្លង់ភ្ជាប់មកជាមួយស្រាប់ ។

ខ – ត្រូវធ្វើរបងហ៊ុំព័ទ្ធជុំវិញបរិវេណទីដីប្រើប្រាស់របស់រោងចក្រ ។

គ – ឈើមូលដែលដឹកជញ្ជូនចូលក្នុងបរិវេណរោងចក្រក្ដារបន្ទះ និងកែច្នៃគ្រឿងសង្ហារឹមត្រូវមានលិខិតអនុញ្ញាតដឹកជញ្ជូនរបស់អង្គការរុក្ខាប្រមាញ់តាមជាប់ជាមួយផង ។

ឃ – ត្រូវសម្រួលដល់មុខនាទីសមត្ថកិច្ចរុក្ខាប្រមាញ់ចេញ–ចូល ធ្វើការត្រួតពិនិត្យសកម្មភាពរោងចក្រក្ដារបន្ទះ និងកែច្នៃគ្រឿងសង្ហារឹមគ្រប់ពេលវេលា ។

ង – ផលិតផលឈើកែច្នៃដឹកជញ្ជូនចេញពីបរិវេណរោងចក្រ ត្រូវមានលិខិតអនុញ្ញាតដោយអង្គការរុក្ខាប្រមាញ់មានសមត្ថកិច្ច ។

ច – ត្រូវមានសៀវភៅបញ្ជីតាមដានឈើចេញ–ចូលរោងចក្រ ។

ឆ – ម្ចាស់រោងចក្រត្រូវទទួលខុសត្រូវលើគ្រប់បទល្មើសព្រៃឈើ ដែលកើតមានក្នុង បរិវេណរោងចក្រក្ដារបន្ទះ និងកែច្នៃគ្រឿងសង្ហារឹមរបស់ខ្លួន ។

ជ – ការប្ដូរឈ្មោះ ឬ ផ្ទេររោងចក្រក្ដារបន្ទះ និងកែច្នៃគ្រឿងសង្ហារឹមពីអ្នកកាន់កាប់មួយទៅអ្នកកាន់មួយទៀតត្រូវមានការយល់ព្រមពីក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ ។

ប្រការ ៣ : ប្រកាសអនុញ្ញាតបង្កើតរោងចក្រក្ដារបន្ទះ និងកែច្នៃគ្រឿងសង្ហារឹមនេះ ត្រូវទុកជានិរាករណ៍ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទក្នុងករណីដែលយល់ឃើញ ថាជាការចាំបាច់ ឬ បានប្រព្រឹត្តអំពើល្មើសព្រៃឈើធ្ងន់ធ្ងរ ។

ប្រការ ៤ : អគ្គនាយក – នាយកខុទ្ទកាល័យ – ប្រធានមន្ទីរក្រសួងកសិកម្មរុក្ខា ប្រមាញ់ និងនេសាទ– ប្រធាននាយកដ្ឋានផែនការស្ថិតិ–ប្រធានគណៈកម្មាធិការត្រួតពិនិត្យ ប្រធាននាយកដ្ឋានរុក្ខា ប្រមាញ់–ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ–ប្រធានការិយាល័យរុក្ខាប្រមាញ់ ខេត្តកណ្តាល និងសាមីជនត្រូវ ទទួលបន្ទុករៀង ៗ ខ្លួនអនុវត្តប្រកាសនេះ ។

ប្រការ ៥ : ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ

ហត្ថលេខានិងត្រា

តាវ សេងហួរ

* * *

៦– ទីស្តីការរដ្ឋមន្ត្រីក្រសួងពត៌មាន

ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ០៩ ខែ មករា ឆ្នាំ ១៩៩៧

ប្រកាសលេខ ០០៦/៩៧ ព.ម.ប្រ.ក

អនុញ្ញាតជូនលោក លឹម អៀង

បើកអាជីវកម្មរោងពុម្ពឈ្មោះ លឹម អៀង

រដ្ឋមន្ត្រីក្រសួងពត៌មាន

–បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

–បានឃើញព្រះរាជក្រឹត្យស្តីពីការតែងតាំងរាជរដ្ឋាភិបាលចុះថ្ងៃទី ០១.១១.១៩៩៣

–បានឃើញព្រះរាជក្រម ចុះថ្ងៃទី ២៤–០១–១៩៩៦ ស្តីពីការបង្កើតក្រសួងពតិមាន

–យោងលិខិតជូនដំណឹងរបស់ក្រសួងពតិមានលេខ ១២២៤.៩៤ ព.ម ចុះថ្ងៃទី ១៤–១១– ១៩៩៤ ស្តីពីការបោះពុម្ពផ្សាយ

_យោងលិខិតស្នើសុំអនុញ្ញាតច្បាប់ បើកអាជីវកម្មរោងពុម្ព « **លឹម សៀវ** » របស់លោក **លឹម សៀវ** ចុះថ្ងៃទី ១៦_១២_១៩៩៦

សំរេច

ប្រការ ១ : អនុញ្ញាតជូនលោក **លឹម សៀវ** ស្ថិតនៅផ្ទះលេខ 83 DEo ផ្លូវលេខ ១៣៩ សង្កាត់ អូរឫស្សីទី ៣ ខ័ណ្ឌ ៧ មករា រាជធានីភ្នំពេញបើកអាជីវកម្មរោងពុម្ព ដែលមានឈ្មោះ « **លឹម សៀវ** » ទីតាំងស្ថិតនៅផ្ទះលេខ 83 DEo ផ្លូវលេខ ១៣៩ សង្កាត់ អូរឫស្សីទី ៣ ខ័ណ្ឌ ៧ មករា រាជធានីភ្នំពេញ ។

ប្រការ ២ : រាល់ដំណើរការបោះពុម្ពផ្សាយ ត្រូវអនុវត្តតាមកិច្ចសន្យាសមស្របតាមទំនៀមទំលាប់សន្តិសុខសណ្តាប់ធ្នាប់សង្គម និង ច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តល្មើសដូចមានចែងក្នុងប្រការ ២ សាមីខ្លួនត្រូវទទួលខុសត្រូវតាមច្បាប់ជាធរ មាន ។

ប្រការ ៤ : ប្រធាននាយកដ្ឋានគ្រប់គ្រងការបោះពុម្ពផ្សាយ និងសោតទស្សន៍ នៃ ក្រសួងពត៌មាននិង ប្រធានមន្ទីរពត៌មានរាជធានីភ្នំពេញ ត្រូវទទួលអនុវត្តតាម ភារកិច្ចរៀង ៗ ខ្លួន ។

ប្រការ ៥ : ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ជ.រដ្ឋមន្ត្រី
រដ្ឋលេខាធិការ
ហត្ថលេខានិងត្រា
ខៀវ កាញារីទ្ធ

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ១០ ខែ មករា ឆ្នាំ ១៩៩៧

ប្រកាសលេខ ០០៧/៩៧

អនុញ្ញាតអោយប្រព្រឹត្តិបំត្រូវឈ្មោះ

«វិទ្យាស្ថានខ្មែរ សំរាប់សហប្រតិបត្តិការ និង សន្តិភាព »

បោះពុម្ពចែកផ្សាយ

– **បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ជំពូក ៣ មាត្រាទី ៤១**

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា។
- បានឃើញច្បាប់ ស្តីពីរបបសារពត៌មាន នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើអោយតាម ព្រះរាជក្រមលេខ ន.ស/រ ក.ម ០៨៩៥-០៧ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥ ។

- បានឃើញសំណើសុំបោះពុម្ពផ្សាយព្រឹត្តិប័ត្រឈ្មោះ" វិទ្យាស្ថានខ្មែរ សំរាប់សហប្រតិបត្តិការ និង សន្តិភាព" ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ១៩៩៦ ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយព្រឹត្តប័ត្រឈ្មោះ" វិទ្យាស្ថានខ្មែរ សំរាប់សហប្រតិបត្តិការ និង សន្តិភាព" បោះពុម្ពចែកផ្សាយដោយមានលោក **កៅ គីមហួន** ជាចាងហ្វាងការផ្សាយ ។ ទីស្នាក់ការបន្ទប់លេខ ១ ហ្សេ វិមានរាជរដ្ឋាភិបាល តិរិវិថី ស៊ីសុវត្ថិ វត្ត ភ្នំ ភ្នំពេញ ។ ក្នុងករណីមានការផ្លាស់ប្តូរនូវចំណុចណាមួយក្នុងអត្តសញ្ញាណ នៃ ព្រឹត្តិប័ត្ររបស់ខ្លួនត្រូវជូនដំណឹងជាមុន ៥ ថ្ងៃ មកក្រសួងពត៌មាន ដើម្បីរង់ចាំសេចក្តីសំរេចជាថ្មី ។

ប្រការ ២ : រាល់ដំណើរការបោះពុម្ពចែកផ្សាយត្រូវគោរពតាមគោលការណ៍ក្រមសីលធម៌ អ្នកសារពត៌មាន និង ឈរលើស្មារតីទទួលខុសត្រូវខ្ពស់ក្នុងវិជ្ជាជីវៈរបស់ខ្លួន ។ ខ្លឹមសារអត្ថបទត្រូវអនុវត្តអោយបានសមស្របតាមទំនៀមទំលាប់ប្រពៃណីល្អ និងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និង ស្នើប្រគល់ព្រឹត្តិប័ត្រចំនួន ៦ ច្បាប់ រៀងរាល់លេខចេញផ្សាយមកតំកល់ទុកជាឯកសារនៅក្រសួងពត៌មាន ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តល្មើសអំពីសេចក្តីដូចមានចែងក្នុងប្រការ ១ និង ប្រការ ២ ខាងលើសាម៉ីខ្លួនត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៤ : លោកអគ្គនាយករដ្ឋបាល និង ហិរញ្ញវត្ថុ លោកប្រធាននាយកដ្ឋានមណ្ឌលពត៌មាន នៃក្រសួងពត៌មាន និងលោកចាងហ្វាងព្រឹត្តិប័ត្រ " វិទ្យាស្ថានខ្មែរ សំរាប់ សហប្រតិបត្តិការ និង សន្តិភាព" ត្រូវអនុវត្តនូវប្រកាសនេះ ។

ប្រការ ៥ : ប្រកាសនេះ មានប្រសិទ្ធិភាពរយៈពេល ២ ឆ្នាំ និងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ ។

រដ្ឋមន្ត្រី
រដ្ឋលេខាធិការ
ហត្ថលេខានិងត្រា
ខៀវ កាញារីទ្ធ

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ១៩៩៧

ប្រកាសលេខ ០០៨/៩៧ ពម.ប្រក
អនុញ្ញាតអោយសារពត៌មាន «ផ្កាយព្រឹក »
បន្តការចេញផ្សាយរបស់ខ្លួនឡើងវិញ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ជំពូក ៣ មាត្រាទី ៤១
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះជណាចក្រកម្ពុជា។
- បានឃើញច្បាប់ ស្តីពីរបបសារពត៌មាន នៃព្រះរាជណាចក្រកម្ពុជា ដែលប្រកាសអោយប្រើអោយតាម ព្រះរាជក្រមលេខ ន.សរ ក.ម ០៨៩៥-០៧ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥ ។
- បានឃើញសំណើសុំបន្តចេញផ្សាយសារពត៌ឈ្មោះ" ផ្កាយព្រឹក" របស់លោក សុខ សឿង ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៩៦ ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយសារពត៌មាន" ផ្កាយព្រឹក" បន្តការចេញផ្សាយរបស់ខ្លួនឡើងវិញ ដោយមាន លោក សុខ សឿង ជាចាងហ្វាងការផ្សាយ ។ ទីស្នាក់ការផ្ទះលេខ ១៣៤ ផ្លូវលេខ ២ ខ័ណ្ឌមានជ័យ ក្រុងភ្នំពេញ ។ ក្នុងករណីមានការផ្លាស់ប្តូរនូវចំណុចណាមួយក្នុងអត្តសញ្ញាណ នៃកាសែតរបស់ខ្លួន ត្រូវជូនដំណឹងជាមុន ៥ ថ្ងៃ

មកក្រសួងពត៌មាន ដើម្បីរង់ចាំសេចក្ដីសំរេចជាថ្មី ។

ប្រការ ២ : រាល់ដំណើរការបោះពុម្ពចែកផ្សាយត្រូវគោរពតាមគោលការណ៍ក្រមសីលធម៌អ្នកសារពត៌មាន និង ឈរលើស្មារតីទទួលខុសត្រូវខ្ពស់ក្នុងវិជ្ជាជីវៈរបស់ខ្លួន ។ ខ្លឹមសារអត្ថបទត្រូវអនុវត្ត អោយបានសមស្របតាមទំនៀមទំលាប់ប្រពៃណីល្អ និងច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា និង ស្នើប្រគល់ កាសែតចំនួន ៦ ច្បាប់ រៀងរាល់លេខចេញផ្សាយមកតំកល់ទុកជាឯកសារ នៅក្រសួងពត៌មាន ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តល្មើសអំពីសេចក្ដីដូចមានចែងក្នុងប្រការ ១ និង ប្រការ ២ ខាងលើនេះសាម៉ីខ្លួន ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៤ : អគ្គនាយករដ្ឋបាល និង ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានមណ្ឌលពត៌មាន នៃក្រសួងពត៌មាន និងលោកចាងហ្វាងសារពត៌មាន " ផ្កាយព្រឹក " ត្រូវអនុវត្តន៍នូវប្រកាសនេះ ។

ប្រការ ៥ : ប្រកាសនេះ មានប្រសិទ្ធភាពរយៈពេល ២ ឆ្នាំ និងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី
រដ្ឋលេខាធិការ
ហត្ថលេខានិងត្រា
ខៀវ កាញារីទ្ធ

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៧

ប្រកាសលេខ ០១១/៩៧

អនុញ្ញាតអោយលោក នយ ជុនឃួន

បើកសេវាកម្មផ្សព្វផ្សាយពាណិជ្ជកម្ម

រដ្ឋមន្ត្រីក្រសួងពត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១-១១-១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។

- បានឃើញព្រះរាជក្រម ចុះថ្ងៃទី ២៤-០១-១៩៩៦ ស្ដីពីការបង្កើតក្រសួង ពិមាន ។
- យោងលិខិតសំណើសុំអនុញ្ញាតបើក សេវាកម្មផ្សព្វផ្សាយពាណិជ្ជកម្មនៅ ព្រះរាជាណាចក្រកម្ពុជា " ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ១៩៩៦ ។

សម្រេច

ប្រការ ១ : អនុញ្ញាតជូនលោក ឆយ ជុងហ្វូន " J.H CHOI " អោយបើកសេវាកម្មផ្សព្វផ្សាយពាណិជ្ជកម្ម នៅព្រះរាជាណាចក្រកម្ពុជា ឈ្មោះ ASIA ADVERTISEMENT CO,LTD ស្ថិតនៅផ្ទះលេខ ៦៣.៦៤.៦៨ ផ្លូវលេខ ១០៨ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

ប្រការ ២ : រាល់ដំណើរការផ្សព្វផ្សាយពាណិជ្ជកម្ម ត្រូវគោរពតាមកិច្ចសន្យាមិន ត្រូវប៉ះពាល់ដល់វប្បធម៌ប្រពៃណីខ្មែរ និងសន្តិសុខសណ្ដាប់ធ្នាប់សង្គម ហើយត្រូវអនុវត្តតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តល្មើសដូចមានចែងក្នុងប្រការ ២ សាមីខ្លួន ត្រូវទទួលខុសត្រូវតាមច្បាប់ជាធរមាន ។

ប្រការ ៤ : ប្រធាននាយកដ្ឋានគ្រប់គ្រងការបោះពុម្ពផ្សាយ និង សោតទស្សន៍ នៃក្រសួងព័ត៌មាន ប្រធានមន្ទីរព័ត៌មានរាជធានីភ្នំពេញ និង អាជ្ញាធរដែលពាក់ព័ន្ធ ត្រូវទទួលអនុវត្តតាមភារកិច្ចរៀងៗខ្លួន ។

ប្រការ ៥ : ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

រដ្ឋលេខាធិការ

ហត្ថលេខា

ខៀវ កាញារីទ្ធ

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៧

ប្រកាសលេខ ០១២/៩៧ ពម.ប្រក

ស្ដីពីការតែងតាំងមន្ត្រីរាជការ

រដ្ឋមន្ត្រីក្រសួងព័ត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១–១១–១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញព្រះរាជក្រម លេខ ០២ នស ៩៤ ចុះថ្ងៃទី ២០–៧–១៩៩៤ ប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិ នៃគណៈរដ្ឋមន្ត្រី ។
- បានឃើញព្រះរាជក្រមលេខ ០១៩៦–១៤ នស.រកម ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការប្រកាសអោយប្រើច្បាប់បង្កើតក្រសួងពត៌មាន ។
- ពិនិត្យលក្ខណៈសម្បត្តិរបស់មន្ត្រីរាជការ ។

សំរេច

ប្រការ ១ : តែងតាំងលោក **ស៊ិម រដ្ឋ** ជាអនុប្រធាននាយកដ្ឋាន សហប្រតិបត្តិការអន្តរជាតិ នៃក្រសួងពត៌មាន ។

ប្រការ ២ : ឯកឧត្តមអគ្គនាយករដ្ឋបាល ហិរញ្ញវត្ថុ លោកនាយកខុទ្ទកាល័យ លោកប្រធាននាយកដ្ឋានបុគ្គលិក លោកប្រធាននាយកដ្ឋានផែនការ គណនេយ្យ ហិរញ្ញវត្ថុ លោកប្រធាននាយកដ្ឋាន សហប្រតិ បត្តិការអន្តរជាតិ និង សាម៉ីខ្លួនមានភារៈអនុវត្តតាមប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

អៀង មូលី

* * *

៧_ ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៧

ប្រកាសលេខ ៤៤ អយក.ប្រក

ស្តីពីការប្តូរឈ្មោះសាលាបឋមសិក្សា តុខ រ៉ូខ មកជា

សាលាបឋមសិក្សា ហ៊ុន សែន មុនីវង្ស

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តមសីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណា ចក្រកម្ពុជា ចុះថ្ងៃទី ០១–១១–១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល ។
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម ចុះថ្ងៃទី ២០–០៧–១៩៩ ។
- បានឃើញព្រះរាជក្រឹត្យលេខ សន.រកត ០៧៩៦–៥២ ចុះថ្ងៃទី ២៦ ខែ ៧ ឆ្នាំ ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ ឆ្នាំ ។
- បានពិនិត្យលិខិតស្នើសុំរបស់សមាគមមាតាបិតាសិស្ស ទ្រទ្រង់សាលាបឋមសិក្សា តុង រ៉ុង ចុះថ្ងៃទី ០៧–មីនា– ១៩៩៦
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំនេះទូទៅ និង មត្តេយ្យសិក្សា

សំរេច

ប្រការ ១ : អនុញ្ញាតអោយមន្ទីរអប់រំយុវជន និងកីឡា ខេត្តកំពង់ចាម ប្តូរឈ្មោះសាលាបឋមសិក្សា តុង រ៉ុង នៅឃុំតុង រ៉ុង ស្រុកព្រៃឈរ ខេត្តកំពង់ចាម មកជាសាលាបឋមសិក្សា ហ៊ុន សែន មុនីរង្សី វិញ ចាប់ពីឆ្នាំសិក្សា ១៩៩៦–៩៧ នេះតទៅ ។

ប្រការ ២ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៣ : លោកប្រធានមន្ទីរក្រសួងអប់រំយុវជន និង កីឡា លោកប្រធាននាយកដ្ឋានចាត់តាំង លោកប្រធាននាយកដ្ឋានផែនការ–ហិរញ្ញកិច្ច លោកប្រធាននាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា លោកប្រធានមន្ទីរអប់រំ និង កីឡាខេត្តកំពង់ចាម លោកប្រធានការិយាល័យអប់រំយុវជន និង កីឡាស្រុកព្រៃឈរ លោកនាយកសាលាបឋមសិក្សាហ៊ុន សែន មុនីរង្សី មានភារកិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

គា សាឃាន

រាជធានីភ្នំពេញ,ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៧

ប្រកាសលេខ ៤៦ អយក.ប្រក

ស្តីពីការបើកអនុវិទ្យាល័យទួលសំពៅ

ក្នុងឃុំព្រាំងស្វាយ ខេត្តព្រៃវែង

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេចព្រះ **នរោត្តមសីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណា ចក្រកម្ពុជា ចុះថ្ងៃទី ០១-១១-១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល ។
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០-៧-១៩៩៤ ។
- បានឃើញព្រះរាជក្រឹត្យលេខ សន.រកត ០៧៩៦-៥២ ចុះថ្ងៃទី ២៦ ខែ ៧ ឆ្នាំ ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ ឆ្នាំ ។
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទម ចុះថ្ងៃទី ០២ ខែ មេសា ១៩៩៣ ស្តីពីការបើកសាលាបឋមសិក្សាកំរិត ១ _ កំរិត ២ ។
- យោងលិខិតស្នើរបស់គណៈកម្មការសាងសង់សាលារៀន ចុះថ្ងៃទី ០៥ មិថុនា ១៩៩៦ ដោយមានយោបល់ឯកភាពពីប្រធានមន្ទីរអប់រំយុវជន និង កីឡា និង អភិបាលខេត្តព្រៃវែង ។
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំនេះទូទៅ និង មត្តេយ្យសិក្សា

សំរេច

ប្រការ ១ : អនុញ្ញាតអោយមន្ទីរអប់រំយុវជន និងកីឡា ខេត្តព្រៃវែងបើកអនុវិទ្យាល័យដែលឈ្មោះថា « អនុវិទ្យាល័យ ទួលសំពៅ ចាប់ពីឆ្នាំសិក្សា ១៩៩៦_៩៧ តទៅ ។

ប្រការ ២ : អនុវិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និង នាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ មួយចំនួនទៀតតាមអង្គការលេខ នៃអនុវិទ្យាល័យ ។

ប្រការ ៣ : នាយក_នាយករងនៃអនុវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចរបស់នាយក នាយករងនៃអនុវិទ្យាល័យ ។

ប្រការ ៤ : ប្រធានមន្ទីរ លោកប្រធាននាយកដ្ឋានចំណេះទូទៅ និង មធ្យមសិក្សា ប្រធាននាយកដ្ឋាន បុគ្គលិកប្រធាននាយកដ្ឋានផែនការ–ហិរញ្ញកិច្ច នៃអប់រំ និងកីឡាខេត្តព្រៃវែងនិងអនុវិទ្យាល័យសាមីមានភារកិច្ចរៀងៗខ្លួនអនុប្រកាសនេះ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

គា សាមាន

* * *

៨– ឱស្តីការរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

រាជធានីភ្នំពេញ,ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ១៩៩៧

ប្រកាសលេខ ៦៤ ប្រក.អជប

ស្តីពីការចាត់តាំងមន្ត្រីរាជការលទ្ធកម្មសាធារណៈ គណៈកម្មាធិការកំណត់មុខលក្ខណសម្បត្តិវាយតម្លៃ និងប្រគល់កិច្ចសន្យា និងគណៈកម្មាធិការត្រួតពិនិត្យចំលងការលទ្ធកម្មប្រចាំអភិវឌ្ឍន៍ជនបទ

រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
– បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះ រាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១–១១–១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
– បានឃើញព្រះក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
– បានឃើញរាជក្រមលេខ ០១៩៦.១២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ ។

– បានឃើញអនុក្រឹត្យលេខ ៦០ អន.ក្រម.ក ចុះថ្ងៃទី ៣១ ខែ ៧ ឆ្នាំ ១៩៩៥ ស្តីពីការគ្រប់គ្រង លទ្ធកម្មសាធារណៈ ។

– បានឃើញសារាចរណែនាំលេខ ០០៦ សណន.សហវ.ស ចុះថ្ងៃទី ១៤–១១–១៩៩៥ ស្តីពីការ អនុវត្តវិធាន និងបទបញ្ញត្តិក្នុងការគ្រប់គ្រង លទ្ធកម្មសាធារណៈរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

– យោងការងារចាំបាច់របស់ក្រសួងអភិវឌ្ឍន៍ជនបទ ។

សំរេច

ប្រការ ១ : តាំងតាំងមន្ត្រីរាជការនៅនាយកដ្ឋានផ្គត់ផ្គង់ហិរញ្ញវត្ថុចំនួន ០៤ រូប អោយទទួលបន្ទុកការងារលទ្ធកម្មសាធារណៈ នៃក្រសួងអភិវឌ្ឍន៍ជនបទបន្ថែមលើការងារបច្ចុប្បន្នដូចមានរាយនាមខាងក្រោមនេះ :

១–លោក **ស្វាយ វ៉េត** ប្រធាន

២–លោក **អ៊ំកេសណ្ណារ៉េត** អនុប្រធាន

៣–លោក **ចាន់ សុវណ្ណនី** សមាជិក

៤–លោក **ស៊ុន ឈាង** សមាជិក

ប្រការ ២ : បង្កើតគណៈកម្មធិការកំណត់បុរេលក្ខណៈសម្បត្តិវាយតម្លៃ និង ប្រគល់កិច្ចសន្យា ដែលមាន សមាសភាពដូចតទៅ : ។

១–ឯកឧត្តម **សំ ឧត្តរ៍** អនុរដ្ឋលេខាធិការ ប្រធាន

២–ឯកឧត្តម **ឡី មេង** អគ្គនាយកបច្ចេកទេស អនុប្រធាន

៣–លោក **សោម សារ៉ន** ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ សមាជិក

៤–លោក **អៀង គីមឡាយ** នាយខុទ្ទកាល័យ សមាជិក

៥–លោក លោកស្រីប្រធានមន្ទីរអង្គភាពពាក់ព័ន្ធគំរោង សមាជិក

៦–លោក **អ៊ំកេសណ្ណារ៉េត** មន្ត្រីលទ្ធផលកម្មសាធារណៈ លេខាធិការ

ប្រការ ៣ : បង្កើតគណៈកម្មាធិការត្រួតពិនិត្យចំលងការលទ្ធកម្ម ដែលមានសមាសភាពដូចតទៅ

១–អ្នកអង្គម្ចាស់ **សុសុខវត្តិ តានុវ៉ត្ត** នាយកខុទ្ទកាល័យ ប្រធាន

២–លោក **សុខ ជឿន** តំណាងអគ្គាធិការដ្ឋាន អនុប្រធាន

៣–លោក **សាម សាយ** អនុប្រធាននាយកដ្ឋានផ្គត់ផ្គង់ហិរញ្ញកិច្ច សមាជិក

៤–តំណាងនាយកដ្ឋានបច្ចេកទេស សមាជិក

៥–តំណាងអគ្គនាយកដ្ឋានផែនការ សមាជិក

៦–តំណាងអង្គភាពត្រួតពិនិត្យរបស់ក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុប្រចាំក្រសួងអភិវឌ្ឍន៍ជនបទ សមាជិក

ប្រការ ៤ : មន្ត្រីលទ្ធកម្មសាធារណៈ គណៈកម្មាធិការកំណត់បុរេលក្ខណៈសម្បត្តិវាយតម្លៃ និងប្រគល់កិច្ចសន្យា និងគណៈកម្មាធិការត្រួតពិនិត្យចំលងការលទ្ធកម្មមាន តួនាទីភារកិច្ចដូចតទៅ :

– អនុវត្តន៍អោយបានត្រឹមត្រូវល្អប្រសើរតាមអនុក្រឹត្យលេខ ៦០ អនក្របក ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៥ និង សារាចរណែនាំលេខ ០០៦ សណនសហវសស ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការអនុវត្តនីតិវិធានការ និង បទបញ្ញត្តិក្នុងការគ្រប់គ្រងលទ្ធកម្មសាធារណៈរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ប្រការ ៥ : រាល់សេចក្តីសំរេចណាដែលផ្ទុយពីសេចក្តីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៦ : ខុទ្ទកាល័យ អគ្គនាយកដ្ឋានទាំង ២ អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន គ្រប់មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត–ក្រុង មជ្ឈមណ្ឌល ព្រមទាំងសាម៉ីជន ដូចមានចែងក្នុងប្រការ ១–២–៣ មានភារកិច្ចអនុវត្តន៍តាមសេចក្តីប្រកាស នេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ឃួន ស៊ុនឃួត

* * *

៩_ ទីស្តីការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ១៩៩៧

ប្រកាសលេខ ០០៦ មន.ប្រក

ស្តីពីថ្លៃសន្ទនាទូរស័ព្ទទៅអន្តរជាតិ

រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តមសីហនុវរ្ម័ន** ចុះថ្ងៃទី ០១-១១-១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ ចុះថ្ងៃទី ០៥-៣-១៩៨៧ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រីអំពីប្រៃសណីយ៍ និងទូរគមនាគមន៍ ។
- បានឃើញសេចក្តីសំរេចលេខ ១៥៤ សសរ ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ១៩៩១ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រីស្តីពីឋានានុក្រមគ្រប់គ្រងតម្លៃ ។
- បានឃើញសំណូមពរចាំបាច់ ។

សំរេច

ប្រការ ១ : កំណត់តម្លៃសន្ទនាទូរស័ព្ទទៅអន្តរជាតិថ្មីដូចមានក្នុងតារាងខាងក្រោមនេះ ។ តម្លៃនេះត្រូវចាប់អនុវត្តពី ថ្ងៃទី ១ ខែ ២ ឆ្នាំ ១៩៩៧ តទៅ ។

ប្រការ ២ : ប្រកាសទាំងឡាយណាដែលមានពីមុន ហើយមានន័យផ្ទុយពីប្រកាសនេះ ត្រូវចាត់ជានិរាករណ៍ ។

ប្រការ ៣ : ខុទ្ទកាល័យ អធិការដ្ឋាន នាយកដ្ឋានផែនការគណនេយ្យ និង ហិរញ្ញកិច្ច នាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស នាយកដ្ឋានទូរគមនាគមន៍អន្តរជាតិ និងនាយកដ្ឋានប្រៃសណីយ៍ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ។

តារាងតម្លៃថ្មី :

១-សម្រាប់ថ្ងៃច័ន្ទ - សុក្រ (តម្លៃធម្មតា)

ជំពន់ **តម្លៃថ្មី**

ប្រទេសឡាវ, វៀតណាម, ថៃ ៣,២០ ដុល្លារ ក្នុង១នាទី

ប្រទេសអាស៊ីដទៃទៀត ៣,៤០ ដុល្លារ ក្នុង១នាទី

ប្រទេសដទៃទៀត ៣,៨០ ដុល្លារ ក្នុង១នាទី

២– តម្លៃថ្ងៃសៅរ៍ និង អាទិត្យ ចុះថ្លៃ ២០% នៃតម្លៃធម្មតា

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

សូ ឃុន

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ១៩៩៧

ប្រកាសលេខ ០០៩ មន. ប្រក

ស្តីពីការតែងតាំងបន្ថែមសមាជិកគណៈកម្មការបច្ចេកទេស

ត្រួតពិនិត្យការងារជួសជុលកែលំអផ្លូវក្នុងរាជធានីក្រោយពី

ការជីកកប់កាប្លិ៍–ទូរស័ព្ទ

យោង : ប្រកាសតែងតាំងគណៈកម្មការបច្ចេកទេសលេខ ១៧៥ បទ–ខល ចុះថ្ងៃទី ២១–១០–១៩៩៦

យោង : ស្មារតីអង្គប្រជុំនៅសាលាក្រុងនាថ្ងៃទី ២៧–១២–១៩៩៦

សំរេច

ប្រការ ១ : តែងតាំងបន្ថែមសមាជិកគណៈកម្មការត្រួតពិនិត្យការងារជួសជុល កែលំអផ្លូវក្នុងរាជធានីក្រោយពីការជីកកប់កាប្លិ៍ទូរស័ព្ទមានសមាសភាពដូចខាងក្រោម:

១–តំណាងសាលាក្រុងភ្នំពេញ

២–តំណាងខ័ណ្ឌដូនពេញ

៣–តំណាងខ័ណ្ឌ ៧ មករា

៤– តំណាងខ័ណ្ឌចំការមន

៥–តំណាងខ័ណ្ឌ ទួលគោក

៦–តំណាងខ័ណ្ឌ ឫស្សីកែវ

៧–តំណាងខណ្ឌ មានជ័យ

៨–តំណាងខណ្ឌ ដង្កោ

ប្រការ ២ : គណៈកម្មការដែលតែងតាំងបន្ថែមថ្មីនេះមានភារកិច្ចចូលរួមសហការយ៉ាងជិតស្និទ្ធជាមួយគណៈកម្មការបច្ចេក ទេសត្រួតពិនិត្យការងារជួសជុល កែលំអ ផ្លូវក្នុងរាជធានីដែលបានតែងតាំងដោយប្រកាស លេខ ១៧៥ បទ.ខល ចុះថ្ងៃទី ២១–១០–១៩៩៦ ។

ប្រការ ៣ : គ្រប់សមាជិកគណៈកម្មការដែលបានតែងតាំងបន្ថែមថ្មីនេះត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

ប្រការ ៤ : ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

សូ យុន

* * *

១០– ទីស្តីការក្រសួងធម្មការ និង សាសនា

សេចក្តីសំរេច

រាជធានីភ្នំពេញ,ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ១៩៩៧

សេចក្តីសំរេចលេខ ០៥/៩៧ ត.ធ.ស

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១–១១–១៩៩៣

– បានឃើញច្បាប់ ស្តីពីការបង្កើតក្រសួងធម្មការ និង សាសនា ដែលប្រកាសអោយប្រើតាមព្រះរាជក្រមលេខ ន.ស.រកម.០១៩៦.១៩ ចុះថ្ងៃទី ២៤ ខែ

មករា ឆ្នាំ ១៩៩៦ ។

- បានឃើញច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជាលេខ ០៦ នស១៩៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ។
- បានឃើញអនុក្រឹត្យលេខ ២២ អន.ក្រ ចុះថ្ងៃទី ៣០ ខែ ៦ ឆ្នាំ ១៩៩២ ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅ នៃក្រសួងធម្មការ និង សាសនា ។
- បានឃើញពាក្យសុំបើកស្នាក់ការថ្វាយបង្គំព្រះគ្រិស្តនិកាយប្រេសប៊ីតធីរាន របស់លោក **ចណ្ណ មុីនរេន** ចុះថ្ងៃទី ០៥–៩–១៩៩៦
- លិខិតបញ្ជាក់ការយល់ព្រមអំពីទីតាំងរបស់ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ លេខ ៣៧៩៥ ព.ត.ស ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦ ។

សំរេច

ប្រការ ១ : អនុញ្ញាតជាគោលការណ៍អោយបើកស្នាក់ការ ថ្វាយបង្គំព្រះគ្រិស្ត និកាយប្រេសប៊ីតធីរាននៃព្រះវិហារឈ្មោះ" ពួកជំនុំប្រេសប៊ីតធីរានភ្នំពេញ" មួយកន្លែង ដែលមានទីតាំងស្ថិតនៅផ្ទះលេខ ១៣១ ផ្លូវលេខ ១៩២ សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

ប្រការ ២ : ស្នាក់ការថ្វាយបង្គំព្រះគ្រិស្ត នៃព្រះវិហារឈ្មោះ" ពួកជំនុំប្រេសប៊ីតធីរានភ្នំពេញ" ត្រូវអនុញ្ញាតអោយប្រើប្រាស់ និងផ្សព្វផ្សាយនូវរាល់ឯកសារផ្សេង ៗរបស់លទ្ធិសាសនាគ្រិស្តដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

ប្រការ ៣ : បរិស័ទទាំងអស់របស់ព្រះវិហារឈ្មោះ "ពួកជំនុំប្រេសប៊ីតធីរានភ្នំពេញ" ត្រូវគោរព និងអនុវត្តអោយបានត្រឹមត្រូវ មុឹងម៉ាត់តាមច្បាប់ តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងរាល់បទបញ្ញត្តិផ្សេងៗរបស់ក្រសួងធម្មការ និងសាសនា ។អ្នកដឹកនាំស្នាក់ការខាងលើនេះ ត្រូវមានសាមគ្គីភាព និង ទំនាក់ទំនងអោយបានល្អជាមួយស្ថាប័នពាក់ព័ន្ធសន្យាជាដាច់ខាតមិន ធ្វើអោយប៉ះពាល់ដល់សិទ្ធិសេរីភាពខាងជំនឿសាសនា និង សណ្តាប់ធ្នាប់របៀប រៀបរយសង្គម ។

ប្រការ ៤ : រាល់ការអនុវត្តន៍ទាំងឡាយណាដែលផ្ទុយអំពី សេចក្តីសម្រេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៥ : នាយកដ្ឋានសាសនា–មន្ទីរធម្មការ និង សាសនា រាជធានីភ្នំពេញ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ដែលមានភារកិច្ចពាក់ព័ន្ធ ត្រូវសហការណ៍អនុវត្តសេចក្តីសម្រេចនេះអោយមានប្រសិទ្ធភាពខ្ពស់ ។

ប្រការ ៦ : សេចក្តីសម្រេចនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

ហៀង ចន្ទរ័ត្ន

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៧

ប្រកាសលេខ ០៦ ក.ធ.ស ប្រក

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១–១១–១៩៩៣
- បានឃើញព្រះរាជក្រមលេខ នសរកម ០១៩៦–១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស អោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និង សាសនា ។
- បានឃើញច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជាលេខ ០៦–១៩៩៤ នស ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ។
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ ខែ ៦ ឆ្នាំ ១៩៩២ ដែលរៀបចំនិងប្រព្រឹត្តិទៅ នៃក្រសួងធម្មការ និង សាសនា ។
- បានឃើញលិខិតលេខ ៧៤ មធស ចុះថ្ងៃទី ២៥–១០–១៩៩៦ របស់មន្ទីរធម្មការ និង សាសនាខេត្តព្រះវិហារ
- អនុលោមតាមការងារចាំបាច់របស់ក្រសួង ។

សំរេច

ប្រការ ១ : តែងតាំងលោក **ឡាំ-សុ** បច្ចុប្បន្នអនុប្រធានមន្ទីរ ត្រូវបានតែងតាំងជាប្រធានមន្ទីរស្តីទីខេត្តព្រះវិហារជំនួសលោក **ហេង ឡៀន** ដែលទទួលមរណភាព ។

ប្រការ ២ : ខុទ្ទកាល័យនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញកិច្ច "ការិយាល័យបុគ្គលិក" មន្ទីរធម្មការ និង សាសនាខេត្តព្រះវិហារ និង លោក **ឡាំ សុ** ត្រូវអនុវត្តតាមប្រកាសនេះ ។

ប្រការ ៣ : សេចក្តីប្រកាសនេះមានប្រសិទ្ធភាព ចាប់តាំងពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

ហៀន ចន្ទរ័ត្ន

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៧

សេចក្តីសំរេចលេខ ០៧/៩៧ ក.ធ.ស.ឧឧ

ស្តីពីការអនុញ្ញាតអោយកសាងវត្តថ្មី

រដ្ឋលេខាធិការ ក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១-១១-១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា នៃព្រះ រាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និង សាសនា ។
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩២ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅ នៃក្រសួងធមការ និងសាសនា ។

- យោងតាមការឯកភាពរបស់ឯកឧត្តមអភិបាលខេត្តកណ្តាលលេខ ២៨៤ សលា ចុះថ្ងៃទី ១៦ ខែ ១២ ឆ្នាំ ១៩៩៦
- យោងតាមការឯកភាពរបស់មន្ទីរធម្មការ និងសាសនាខេត្តកណ្តាលលេខ ៩៣_៩៦ កធសខ ចុះថ្ងៃទី ០៩ ខែ ១២ ឆ្នាំ ១៩៩៦ ។
- តបតាមសំណូមពររបស់លោក ផូ ខួន តំណាងពុទ្ធបរិស័ទនៅភូមិព្រែកតានប់ ឃុំកំពង់ស្វាយ ស្រុកកៀនស្វាយ ខេត្តកណ្តាល ចុះថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ សុំកសាងវត្តថ្មី ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយកសាងវត្តថ្មីមួយដែលមានឈ្មោះថា " វត្តទួលប្រាសាទប្រាំ " ដែលស្ថិតនៅក្នុងឃុំកំពង់ស្វាយ ស្រុកកៀនស្វាយ ខេត្តកណ្តាល ។

ប្រការ ២ : វត្តនេះ ត្រូវដាក់អោយព្រះសង្ឃពុទ្ធបរិស័ទគោរពប្រតិបត្តិ និងធ្វើបុណ្យទានអោយបានត្រឹមត្រូវតាមពុទ្ធប្បញ្ញត្តិ និងពុទ្ធានុញ្ញាតព្រមទាំងច្បាប់របស់រដ្ឋ ។

ប្រការ ៣ : មន្ទីធម្មការ និងសាសនាខេត្ត–ស្រុក គណៈកម្មការ–អាចារ្យវត្ត និងពុទ្ធបរិស័ទត្រូវសហការណ៍ជាមួយមន្ត្រីសង្ឃខេត្ត–ស្រុក និងរដ្ឋអំណាចគ្រប់លំដាប់ថ្នាក់ ដែលពាក់ព័ន្ធអនុវត្តតាម សេចក្តីសម្រេចនេះអោយបានល្អប្រសើរ និងជួយឧបត្ថម្ភអោយបានសមស្រប ។

ប្រការ ៤ : សេចក្តីសម្រេចនេះមានប្រសិទ្ធភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

ហឿន វណ្ណារិទ្ធ

* * *

១១_ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

សេចក្តីសំរេច

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ១៩៩៧

សេចក្តីសំរេចលេខ ០២១ សស.មស.ក្រខ

ស្តីពីការបែងចែកនិស្សិតចំនួន ២៦ នាក់

ដែលទើបបញ្ចប់ការសិក្សាពីបរទេស

រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១០-១១-១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា ។
- យោងលិខិតលេខ ៣១៩ សជណ.ផក ចុះថ្ងៃទី ២៨ ខែ ០២ ឆ្នាំ ១៩៩៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី

សំរេច

ប្រការ ១ : អ្នកបច្ចេកទេសថ្នាក់បណ្ឌិតវិទ្យាសាស្ត្រគីរិត ១ ចំនួន ២ នាក់ ថ្នាក់ឧត្តមចំនួន ២២ នាក់ និងថ្នាក់មធ្យមចំនួន ២ នាក់ ដែលបានបញ្ចប់ការសិក្សាពីបរទេស ត្រូវបានបែងចែកអោយទៅបំរើការងារ នៅតាមក្រសួងស្ថាប័នមួយចំនួនដូចមាន ក្នុងតារាងឧបសម្ព័ន្ធ នៃសេចក្តីសំរេចនេះ ។

ប្រការ ២ : ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធមានភារកិច្ចទទួលយកអ្នកបច្ចេកទេសទាំងនេះ ដើម្បីរៀបចំការងារអោយត្រូវតាមមុខជំនាញ និងផ្តល់បៀវត្សជូនសាម៉ីជន ចាប់ពីថ្ងៃដែលបានចូលបំរើការងារ ជាផ្លូវការ ។

ប្រការ ៣ : សេចក្តីសម្រេចនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

ប្រាក់ សុខ

* * *

តារាងឧបសម្ព័ន្ធ នៃសេចក្តីសំរេចលេខ ០២១ សសរមស.ក្រខ
ចុះថ្ងៃទី ១៣ ខែ ០១ ឆ្នាំ ១៩៩៧ ស្តីពីការបែងចែកនិស្សិតចំនួន ២៦ នាក់
ដែលទើបបញ្ចប់ការសិក្សាពីក្រៅប្រទេស

ល.រ	នាមត្រកូលនិងនាមខ្លួន	ភេទ	ថ្ងៃខែឆ្នាំកំណើត	អង្គភាពដើម	មុខជំនាញបច្ចេកទេស	បៀវត្ស	ប្រភពបណ្តុះបណ្តាល
	១–នីស្តីការគណៈរដ្ឋមន្ត្រីចំនួន ០៣ នាក់						
	ក–អ្នកបច្ចេកទេសថ្នាក់បណ្ឌិតវិទ្យាសាស្ត្រតែ១ ចំនួន ០២ នាក់ :						
១	គង់ ថៃ	ប	១០–១០–៥៨	សិស្ស	វិទ្យាសាស្ត្រសេដ្ឋកិច្ច	៩០.ខ ៤	២
២	ព្រុំ ទេវី	ស	២១–៨–៦៥	សិស្ស	ប្រវត្តិសាស្ត្រ និងសង្គម សេដ្ឋកិច្ចកម្ពុជា	៩០.ខ ៤	២
	ខ–អ្នកបច្ចេកទេសថ្នាក់ឧត្តមចំនួន ០១ នាក់						
៣	គុជ ហ៊្សិនី	ប	២៩–៨–៦៩	សិស្ស	ភូមិវិទ្យា	៩០.ខ ၊១	១
	២–ក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល						
	អ្នកបច្ចេកទេសថ្នាក់ឧត្តមចំនួន ០១ នាក់						
៤	គង់ កុសល	ប	០៣–៣–៧០	សិស្ស	អគ្គិសនីផ្នែកប្រព័ន្ធបណ្តាញ	៩០.ខ១	៦
	៣–ក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ						
	ក–អ្នកបច្ចេកទេសថ្នាក់ឧត្តមចំនួន ០២ នាក់						
៥	ចាច់ សុវណ្ណា	ប	១៧–០១–៦៩	សិស្ស	វិស្វអគ្គិសនីផ្នែកកសិកម្ម	៩០.ខ ၊១	១
៦	ហោ ដារ៉ា	ប	០១–០១–៧០	សិស្ស	រុក្ខកម្ម	៩០.ខ ၊១	៤
	ខ–អ្នកបច្ចេកទេសថ្នាក់មធ្យមចំនួន ០១ នាក់						
៧	ជា សារិន	ប	០៣–៣–៧០		មន្ទីរគមនាគមន៍ដឹកជញ្ជូនរថយន្ត ខេត្តព្រៃវែង	.ខ ၊၊១	១
	៤–ក្រសួងសាធារណការ និង ដឹកជញ្ជូនចំនួន ១២ នាក់						
	ក–អ្នកបច្ចេកទេសថ្នាក់ឧត្តមចំនួន ១១ នាក់						
៨	ជាវង្ស សុជាតិ	ប	១២–៤–៧១	សិស្ស	សំណង់ផ្លូវថ្នល់ និង ព្រលានយន្តហោះ	៩០.ខ ၊១	១

៩	វែក សុវណ្ណ	ប	០៨–៤–៧០	សិស្ស	សំណង់ស៊ីវិលនិងឧស្សាហកម្ម	៩០.ខ I១	១
១០	សេក សុធីរិទ្ធ	ប	០៥–១០–៦៨	សិស្ស	ស្ថាបត្យកម្ម	៩០.ខ I១	៣
១១	មាស គីរីផល	ប	១៥–០១–៦៨	សិស្ស	រថយន្ត	៩០.ខI១	៦
១៣	យ៉ង សុបញ្ញា	ប	១០–១០–៦៨	សិស្ស	ស្ថាបត្យកម្ម	៩០.ខ I១	៦
១៤	ស្វ ពណ្ណារិទ្ធ	ប	០៣–០៦–៧០	សិស្ស	សំណង់ស៊ីវិល	៩០.ខ I១	៤
១៥	ឱកប្ញ	ប	០៥–៤–៦៦	សិស្ស	ស្ថាបត្យកម្ម	៩០.ខ I១	៦
១៦	កែវ ម៉ុនជ័យ	ប	០៨–៤–៦៩	សិស្ស	ស្ថាបត្យកម្ម	៩០.ខ I១	៦
១៧	ញ៉ែម ចាន់ដារ៉ា	ប	០៣–៣–៦៦	សិស្ស	ស្ថាបត្យកម្ម	៩០.ខ I១	៦
១៨	ឯកសុភា	ប	១២–៨–៦៥	ក្រុមហ៊ុនស្ថាបនា ពាណិជ្ជកម្មមល្បឹម	ស្ថាបត្យកម្ម	៩០.ខ I១	១

ខ—អ្នកបច្ចេកទេសថ្នាក់មធ្យមចំនួន ០១ នាក់

១៩	អ៊ុង ច័ន្ទដារា	ប	០៥–០១–៧១	សិស្ស	ជួសជុលនិងថែទាំរថយន្ត	៩០.ខ II១	១

៥—ក្រសួងពាណិជ្ជកម្មចំនួន ០២ នាក់

អ្នកបច្ចេកទេសថ្នាក់ឧត្តមចំនួន ០២ នាក់

២០	ម៉ា រ៉ាមី	ប	០៥–៤–៦៩	សិស្ស	បច្ចេកវិទ្យាស្បែក និងរោមសត្វ	៩០.ខ I១	១
២១	ប៊ុន ចំណាន	ស	០២–០២–៧៤	សិស្ស	សេដ្ឋកិច្ច និងការគ្រប់គ្រងសហគ្រាស	៩០.ខ I១	១

៦—ក្រសួងផែនការ

អ្នកបច្ចេកទេសថ្នាក់ឧត្តមចំនួន ០១ នាក់

២២	ឯមសំអ៊ា	ប	០៨–៦–៧១	សិស្ស	អភិវឌ្ឍន៍សេដ្ឋកិច្ច	៩០.ខ I១	៦

៧—ក្រសួងសុខាភិបាល ចំនួន ០២ នាក់

អ្នកបច្ចេកទេសថ្នាក់ឧត្តមចំនួន ០២ នាក់

២៣	សាង ចំរើន	ប	០១–៩–៦៨	សិស្ស	វេជ្ជសាស្ត្រទូទៅ	៩០.ខ I១	១
២៤	លី ស្រីវណា	ស	២០–៨–៦៩	សិស្ស	វេជ្ជសាស្ត្រទូទៅ	៩០.ខ I១	៥

៨—ក្រសួងមហាផ្ទៃ

អ្នកបច្ចេកទេសថ្នាក់ឧត្តមចំនួន ០១ នាក់

២៥	ឈីវ គិច	ប	០១–០១–៧១	សិស្ស	ស្ថាបត្យកម្ម	៩០.ខ I១	៦

៩– ក្រសួងព័ត៌មាន

អ្នកបច្ចេកទេសថ្នាក់ឧត្តមចំនួន ០១ នាក់

២៦	ចាន់ វណ្ណា	ប ២៤-៤-៦១	មន្ត្រីអគ្គនាយកដ្ឋាន បច្ចេកទេស ៩០.៩ /១ ២ វិទ្យុជាតិ

កំណត់សំគាល់ : បានបញ្ឈប់បញ្ជីត្រឹមចំនួន ២៦ ម្ភៃប្រាំមួយ នាក់ប៉ុណ្ណោះ ។

១– ប្រទេសរុស្ស៊ី
២– ប្រទេសអាល្លឺម៉ង់
៣– ប្រទេសប៊ុលហ្គារី
៤– ប្រទេសឆេក្ល
៥– ប្រទេសប៉ូឡូញ
៦– ប្រទេសវៀតណាម

រាជធានីភ្នំពេញ,ថ្ងៃទី ១៣ ខែ ០១ ឆ្នាំ ១៩៩៧

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

ប្រាក់ សុខ

* * *

បោះពុម្ពនៅរោងពុម្ព ទីស្ដីការគណៈរដ្ឋមន្ត្រី
លើកទី១ ចំនួន ៨០០ ច្បាប់

តម្លៃ ១៨៧៥ រៀល